
មាក់.ឆៃមុក
សម្បថ
មួយពាន់ពាក្យ
CLPP
ប្ដីស្ត្រីដែលឃ្លាតគូ សូមកុំអាន !

# សម្បថមួយពាន់ពាក្យ

និពន្ធដោយ

ហាក់-ឆៃហុក

Chhay Hok HAK

សមាជិកសមាគមអ្នកនិពន្ធខ្មែរ

ការផ្សាយរបស់

ខៀវ-ស-សេដ្ឋាវុធ

រក្សាសិទ្ធិ

ព.ស. ២៥១៦ គ.ស. ១៩៧២

# ១

## ស្រឡាញ់ពេញចិត្ត

ស្រឡាញ់ពេញចិត្ត ចិត្តមេត្រី
រួមរក្សនិងស្រី ស្រីមេត្តា
ស្នោះស្ម័គ្រ ស្ម័គ្រអស់ពីចិន្តា
ករកើតស្នេហា ស្នេហាថ្ងៃ ។

**ជៀងខ្លាច** ជាអ្នកមានស្តុកស្តម្ភជាងគេឯងទាំងអស់ នៅក្នុងស្រុកមោងឫស្សី (ខេត្តបាត់ដំបង) ស្រែលោកជាង ប្រាំរយហិកតា និងចំការម្នាស់នៅឃុំត្លួយផឹកដីបីរយរ៉ៃទៀត ធ្វើឲ្យលោកបានផលគិតជាប្រាក់ចំណូល យ៉ាងហោចបំផុត ត្រឹមសែសិបម៉ឺនរៀលក្នុងមួយឆ្នាំៗ ។

គិតៗ ទៅមនុស្សដូចជខ្លៅឡាប ដូចជាគ្មានគិតភ័យពីរឿងគ្រោះ បើទុកជាលោកមិនធ្វើស្រែចំការទាំងនោះ គ្រាន់តែជួលឲ្យគេយកប្រាក់ឈ្នួល ក៏លោកអាចរស់នៅបានយ៉ាងសុខស្រួលអស់មួយជីវិត ។

ជខ្លៅឡាប មិនត្រឹមតែជាអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញខាងកោតទ្រព្យប៉ុណ្ណោះទេ លោកនៅមានបុត្រីបណ្តូលបណ្តាច់មួយទៀត ឈ្មោះនាងអម្ពរ រូបសល្អស្រស់ប្រៀបបាននឹងកុលាបស្វគាំ ក្រអូបគន្ធាប្រាស់ខ្យល់គ្រប់ទិសានុទិស ។ ធ្វើឲ្យលោកមានកិត្តិសព្ទល្បីល្បាញខាងមានកូនក្រមុំស្អាតថែមមួយផ្នែកទៀត ។

កម្លោះៗ កូនអ្នកមានស្រុកស្រែជាច្រើនបោមពេមប្រាថ្នាបេះផ្កាកុលាបស្រុកមោងនេះ មកធ្វើជាគូរួមរក្សស្ម័គ្រមេត្រីតែរៀងពល់រូប ។ តែក៏ត្រូវទទួលសេចក្តីអស់សង្ឃឹមត្រឡប់ទៅផ្ទះវិញគ្រប់ៗគ្នា ព្រោះកញ្ញាអម្ពរ ពុំបានទន់ទោរតាមជំនោរខ្យល់កាចាថាស្នេហា ឬប្រគល់បេះដូង

បរិសុទ្ធដូចសំពត់ទេសឯករបស់នាង ទៅឲ្យបុរសណាមួយឡើយ ។

ការពិតក្នុងវ័យក្រមុំរបស់អម្ពរ មិនមែនថានាងមិនចេះស្នេហាទេ នាងជាមនុស្សបថុជ្ជនដូចគេឯងដែរ ជាពិសេសវ័យរបស់នាងកំពុងស្ថិតនៅក្នុងវ័យស្គារ វ័យត្រេកត្រអាលស្រើបស្រាល តែបានជានាងប្រកែកពុំព្រមស្និទ្ធស្នេហាទៅលើបុរសណា ក៏មកពីនាងមានគូប្រចាំចិត្តរួចទៅហើយ គេនោះឈ្មោះទិវាជាកូនអ្នកក្រីក្រទេ ហេតុផលបណ្តាលឲ្យចិត្តនាងស្រឡាញ់គេមកពីនាងសំគាល់ឃើញចិត្តថ្លើមរបស់ទិវាជាសុភាពបុរស ។ ចេះគួរសមរម្យនឹងព្រឹទ្ធាចារ្យ ចរិយាក៏ស្លូតបូតទនលំទោនដឹងបុណ្យដឹងបាប មិនព្រហើនកោងកាចប្រឡឹមប្រឡោងខាម ដូចពពួកកូនកម្លោះអ្នកមាននានា ។ គឺពោលឲ្យចំហើយទ្វី ទិវាមានគ្រប់គ្រាន់ទាំងអស់ ផ្នែកគុណសម្បត្តិ គេខ្វះត្រង់តែទ្រព្យសម្បត្តិមួយយ៉ាងប៉ុណ្ណោះ ។

ថ្ងៃនេះតាំងពីព្រឹកដល់ល្ងាច អម្ពរនាងអង្គុយសំកុកនៅក្នុងបន្ទប់មិនព្រមចេញក្រៅសោះ ភ្នែកទាំងគូរបស់ស្រីក្រមុំដិតជាមទៅដោយតំណក់ទឹកភ្នែក ។

បានជានាងព្រួយចិត្តសោយសោកាដូច្នេះ មកពីលោកជម្ទាវឡាចឪពុកនាង បង្ខំឲ្យនាងព្រមរៀបការជាមួយកូនកម្លោះថៅកែចំការក្រូចម្នាក់នៅសូរដំបង ។ ដោយដាក់កំហិតជម៉ឹងថាត្រូវតែយល់ព្រម ប្រកែកមិនបានជាដាច់ខាត ។

កុលាបស្រុកខ្មែរព្រួយចិត្តណាស់ ព្រោះប្រុសដែលត្រូវជាប្តីនាងក្នុងពេលអនាគតមិនមែនទីរ៉ា ។ នាងចង់ទំលាយការពិតដល់ឪពុកម្តាយថានាងស្រឡាញ់ទីរ៉ាទៅហើយ តែសភាពអៀនប្រៀន ធ្វើឲ្យនាងរកគ្រលាស់អណ្តាតនិយាយមិនរួច ណាមួយនាងខ្លាចពុំបានដូចបំណង នាំឲ្យខកការធំទៀត ។

រាត្រីនេះ ក្រោយពីឪពុកម្តាយនាងចូលសំរាន្តអស់ទៅ

កញ្ញាអម្ពរ  ក៏លួចបើកទ្វារក្រោយចេញទៅជួបទិពក្នុងសួនខាងក្រោយផ្ទះ ដែលជាកន្លែងសំរាប់ណាត់ជួបគ្នាតាំងពីដើមទីមក ។

ទិពសំកុកចាំមើលផ្លូវសង្សារតាំងពីក្បាលព្រលប់  គេគ្រាន់តែឃើញស្រមោលអម្ពរដើរមក គេក៏ស្ទុះទៅទទួលឱបរិតដោយសេចក្ដីស្រឡាញ់ពេញចិត្ត ។

– អូនអម្ពរ ! បងនឹកអូនណាស់ ! បងស្មានថាអូនមិនមកតាមពាក្យសន្យាទេតើ !...

អម្ពរមិនឆ្លើយតប  នាងត្រឡប់ជាយំសសឹក  ធ្វើឲ្យនាយកម្លោះកិតភ័យ  លែងដៃពីឱបសួរទៅសង្សារដោយងឿងឆ្ងល់ថា ៖

– ម្ដេចបានជាអូនយំ? អ្នកណាគេធ្វើបាបអូនឲ្យទទួលសេចក្ដីឈឺចាប់ឬ ?

– ចា៎ះ ! ស្នេហាយើងមានឧបសគ្គធំចូលមកកាំងហើយបង...!

– អ៊ុស ! ស្នេហាយើងមានឧបសគ្គ ?!

ទិព្វឧទានតិច ៗ ។

– ហ៊ះ ! ត្រូវហើយបង ស្នេហាយើងមានឧបសគ្គ !..

និយាយរួច អម្ពរក៏ក្រោបមុខទៅលើទ្រូងប្រុសស្នេហ៍ យំកាន់តែច្រើនឡើង ។

ទិព្វ ដកដង្ហើមធំព្រោះមិនដឹងឫសគល់នៃដើមហេតុ ។ ប្រុសកម្លោះយកដៃអង្អែលកេសាស្រីថ្លៃស្រាល ៗ បានមួយសន្ទុះទើបគេដាច់ចិត្តសួរនាងថា ៖

– រឿងអ្វីទៅអូន ? ប្រាប់បងឲ្យដឹងផងមើល ?

មាណវីងើបមុខចេញពីផ្ទាំងទ្រូង និយាយទៅកាន់ទិព្វ ទាំងនៅលាយយំតិចៗ ៖

– បងអើយ...! ប៉ាអូនគាត់គិតលើកអូនឲ្យមានប្ដីទៅអ្នកចំការក្រូចនៅឯអូរដំបងហើយ... អូនពិបាកចិត្តណាស់! សូមបងជួយរកផ្លូវដោះស្រាយឲ្យអូនផង !...

ពៅមាណពធ្លាក់ថ្លើមក្ដុក វិមានស្នេហ៍ចំពួតដៃគ្នាសាង

អស់ពេលកប់ខែឆ្នាំ ឥឡូវនេះត្រូវព្យុះកម្មផាតបក់រលំរលើង អស់ហើយ ៗ គេឈប់ស្ងៀមមួយស្របក់ ទើបឮខ្សឹ ស្អុះសៀងរើយ ៗ របៀបមនុស្សផុតសង្ឃឹមក្នុងជីវិតថា ៖

– អូនអម្ពរ...! រឿងរបស់យើងនេះពិបាកដោះស្រាយណាស់ ! ខ្ញុំបងប្រៀបដូចសុភាសិតបុរាណពោលថា " ខ្ញុំទាបដៃខ្លីចង់ស្រវាឱបភ្នំ " បងកូនអ្នកក្រ ខ្វះទ្រព្យសម្បត្តិ ខ្វះមាសពេជ្រ ខ្វះអ្វីៗទាំងអស់ ដែលកូនចៅតែគេមាន !... បងនឹកៗទៅតូចចិត្តនឹងវាសនាណាស់អូន ...! បើសិនជាបងមានវាសនា បានកើតឡើងកណ្ដាលពំនូកមាសពំនូកប្រាក់ដូចរូបគេ ប្រហែលជាស្នេហាយើងទាំងពីរនាក់គ្មានឧបសគ្គអ្វីចូលមកពាំងទេ...!

– ទ្រព្យសម្បត្តិ មិនមែនជួយមនុស្សយើងឲ្យសប្បាយទាំងអស់គ្នាទេ បងដូចរូបអូនកើតឡើងកណ្ដាលឃ្លាំងសម្បត្តិ តែបើមិនបានរូបបងមកធ្វើជាមិត្តរួមជីវិត អូនក៏មិនសប្បាយចិត្តដែរ..!

- ពីព្រោះអ្វី ?

ពីព្រោះក្នុងលោកនេះ ក្នុងជាតិនេះ ក្នុងជីវិតនេះ អូនស្រឡាញ់តែបងទិពមួយប៉ុណ្ណោះ បើខ្វះបងទិពជីវិតអូនក៏ជាជីវិតគ្មានខ្លឹមសារអ្វីដែរ !...

បានស្តាប់មធុរសពារបស់អម្ពរ ទិពសែនរីករាយក្នុងហឫទ័យ ស្រាលខ្លួនដូចអណ្តែតទៅលើផ្ទៃអាកាសា ។ គេនឹកសរសើរសំណាងរបស់គេ ពេះធ្វើឲ្យកូនជស្ទៅយ៉ាងនាងមកស្រឡាញ់គេក្រីក្រ រហេមរហាមរកស្រែមួយជ្រុងគ្មាន ។ គេជាសត្វកន្ធង់អនាថា ដែលមានវាសនាបានស្រូបស្រង់ក្លិនគន្ធាកុលាបសួគ៌ានេះ មុនកន្ធង់ឯទៀតៗ ។

តែហើយ . ទិពក៏ត្រូវព្រួយចិត្តឧបក្ខុទុក្ខ មុខលែងស្រស់ទៅវិញ កាលបើគេនឹកឃើញថាស្នេហាគេជាស្នេហាអស់សង្ឃឹម ព្រោះយ៉ាងណាៗ ក៏លោកជស្ទៅឡាបឪពុកនាងមិនព្រមឲ្យនាងមកស្រឡាញ់គេជាដាច់ខាត ។

ទិព ជគជង្គើមធំ មើលទៅដួងព្រះចន្ទ្រាដោយក្រសែ

បក្ខុសោយសោក ៗ នរៈបន្ទិសំនៀងតិចៗទ្រង់បន្ទូលថា៖

- អុំឲអម្ពរ.. ! រឿងយើងទាំងពីរនាក់នេះ បងរកផ្លូវដោះស្រាយមិនទាន់រួចទេ... ចំពោះរឿងស្ដីដណ្ដឹងរបស់កូនចៅកែបំការក្រុបនោះ អូនឆ្លើយយល់ព្រមជាមួយឪពុកអូនយ៉ាងម៉េចខ្លះហើយ ?

អម្ពរគ្រវីក្បាល

- អូនមិនឆ្លើយយ៉ាងណានៅឡើយទេ ! ព្រោះអូនចាំសួរយោបល់បងសិន...!

- យោបល់បងឬ ? ( ទំរាពោល ) ហ៊ឺ ! កុំទាន់ឲ្យបងបញ្ចេញយោបល់ធ្វើអ្វីអូន តែចំពោះអូន ថ្ងៃស្អែកបើលោកឪពុកអូនសួរម្ដងទៀត អូនគិតឆ្លើយយ៉ាងម៉េច ?

- អូននឹងឆ្លើយយ៉ាងខ្លីថា មិនព្រមទទួលកូនចៅកែបំការក្រុបនោះជាដាច់ខាត ៗ

- ចុះប្រសិនបើលោកបង្ខំ ?

- ចា៎ះ ! អូនសុំស្លាប់ !

- អូនមិននឹកស្តាយ កេរ្តិ៍ឈ្មោះកិត្តិយសអូនទេឬ ?

- ចា៎ ! អូននឹកស្តាយដែរ តែអូនស្តាយរូបបងជាជាងអ្វីទាំងអស់ !...

- ហេតុអ្វីបានជាអូនស្រឡាញ់បងខ្លាំងម្ល៉េះ? អូនមិនដឹងថាបងក្រទេឬ ?

- ហេតុអ្វីដែលបណ្តាលឲ្យអូនស្រឡាញ់បង អូនក៏មិនបានដឹងដែរ !.. អូនដឹងគ្រាន់តែថា ចិត្តអូនបង្គាប់ឲ្យស្រឡាញ់បង ស្រឡាញ់ស្មើៗ និងជីវិត រីឯរឿងឋានៈសក្តិយសមានឬក្រ មិនមែនជាបញ្ហាធំដុំចំពោះស្នេហាបរិសុទ្ធឡើយ ។

- ក្នុងលោកនេះ ប្រហែលជាមាននារីតែអូនមួយទេ ដែលមានចិត្តស្មោះស្ម័គ្រប្តូរផ្តាច់ ចំពោះគូសង្សារដូច្នេះ

- ក្នុងលោកនេះ ក៏មានតែបងមួយដែរដែលអូនស្រឡាញ់ !...

និយាយចប់ អម្ពរក៏ផ្ដេកក្បាលទៅនឹងស្មាទិព្វ ។ ប្រុសស្នេហ៍ត្រកងកាយស្រស់ស្រីមកឱបណែនផ្អាប់ទ្រូងៗ យុវជនក្ងើយមុខសង្ហារ ឱនថើបលើក្បួងថ្ពាល់ដ៏ត្រជាក់ស្រឹតប្រកបដោយក្លិនប្រហើររបស់នារីស្រោលៗ ។ បានបន្តិចមក គេក៏និយាយទៅកាន់នាង ៖

- អូនអម្ពរ...! រឿងយើងបងឲ្យយោបល់អូនពេលនេះមិនទាន់បានទេ សូមអូនទុកពេលឲ្យបងគេងគិតបន្តិច!. ចំណែកអូនបើមានការបង្ខិតបង្ខំតឹងរឹងពីឪពុកម្ដាយយ៉ាងណា ចាំយើងដោះស្រាយ នៅពេលជួបគ្នាយប់ក្រោយទៀត ... ឥឡូវអូនត្រឡប់ចូលផ្ទះគេងចុះ សន្សើមធ្លាក់ច្រើនណាស់! យប់នេះពេលអូនគេងលក់ទៅ ចូរអូនយល់សប្ដិល្អហើយយល់សប្ដិឲ្យឃើញបងផងណា៎ ?

- ចា៎ះ! បងទិព្វ! ចំណែកបងអូនក៏សូមឲ្យបងគេងលក់ទៅយល់សប្ដិឃើញអូនដែរ!

យុវសង្ឃទាំងពីរប្រាណាក្រោកឈរ និយាយផ្ដែផ្ដាំមួយម៉ាត់ពីរទៀត ក៏បែកគ្នាគេចបាត់ពីរស្មីព្រះចន្ទនាកត្រីស្ងាត់ក្នុងពេលនោះទៅ ។

*

* *

# ២

## រត់ចោលឪម៉ែតាមសង្សារ

ឪបង្ខំឲ្យ ឲ្យយកប្ដី
ម៉ែសោតអប្រិយ៍ អប្រិយ៍ក្រៃ
វាយកូន កូនឈឺស្ទើរជីពក្ស័យ
លាហើយអ្នកម្ដាយ អ្នកម្ដាយអើយ !

**ថៅ**កែចំការក្រូចនៅអូរជំបង់ អញ្ជើញមកសួរបញ្ជាក់ ពីរឿងកូនប្រុសលោកនិងនាងអម្ពរកុលាបសួគ៌ាម្ដងទៀត ។

លោកជស្នៅឡាចនិងលោកស្រីយឿម ទទួលពាក្យ យល់ព្រមហើយកំណត់ពេលវេលាថ្ងៃការ ឲ្យខាងប្រុសភ្ជាប ដោយមិនចាំសួរសំរេចចិត្តពីកូនស្រីលោក បន្តិច បន្តួច-ទៀយ ។

គ្រាន់តែភ្ញៀវចុះត្រឡប់ទៅវិញអស់   លោកជន្ទោក៏ហៅអម្ពរមកប្រាប់ថា ៖

- អម្ពរកូន ! ថ្ងៃ ១៣ កើតខែផល្គុនខាងមុខនេះ ប៉ារៀបការកូនឲ្យមានប្ដីសីហើយ   កូនមិនត្រូវប្រកែកទេណា !...

អម្ពរ គ្រាន់តែឮថាឪពុកជិតឲ្យមានប្ដី នាងតក់ស្លុតទន់ជង្គង់ស្ទើរដួល ៗ មុខមាត់ពាងកាយញ័រញាក់ទ្រើកៗ ដូចគេថ្ពច ៗ ស្រស់ស្រីហារមាត់និយាយទ្រន់ចង់យំ អង្វរករទៅលោកជន្ទោជាឪពុក៖

- សូមប៉ាអាណិតកូនផង ...! កូនមិនព្រមរៀបការជាមួយកូនកម្លោះលោក.ចៅកែបំការក្រូច   នៅអូរដំបងហ្នឹងទេ ...!

លោកជន្ទោ   បើកភ្នែកធំៗ ប៉ុនពងមាន់   ព្រោះមិននឹកស្មានថាកូនហ៊ានប្រកែក   ៗ   លោកគំហកទៅអម្ពរខ្លាំងៗ វិញដោយមិនពេញចិត្ត ៖

– ទេ ! ឯងត្រូវតែព្រម ប្រកែកមិនបានជាដាច់ខាត !

– ម៉ាក់ទទួលពាក្យសុំដីគេរួចអស់ទៅហើយ ឯងប្រកែកតបឹងយ៉ាងម៉េចកើត !

លោកស្រីយឿមមានប្រសាសន៍បន្ថែម ។

– ខ្ញុំមិនទាន់ចង់បានប្ដីទេម៉ាក់ ? សូមម៉ាក់ជូនពាក្យគេវិញទៅ !

អម្ពរប្រកែក ។

មួងនេះលោកស្រីប្រែទឹកមុខក្រញូវ ផ្លាស់សម្លេងរាជសីហ៍សម្លុតកូនមួយរំពេច ៖

– អញក្បាលចាស់ប៉ុណ្ណឹងហើយ មិនចេះនិយាយម្ដងបាតដៃខ្នងដៃទេវើយ ! បើអញនិយាយស្រួល ៗ ឲ្យចេះស្ដាប់ផង កុំធ្វើឲ្យអញឈួលចុងច្រមុះប្រើធម៌ក្ដៅណា !... ហ៊ឹះ !

– ក៏ប៉ុន្តែ ...

– កុំយកតាពាក្យ ក៏ប៉ុន្តែមកនិយាយជាមួយអញ !

( លោកជង្ហោឡាចស្រែកសន្ធាប់បង្អាក់ប្រយោគកូន ) អញមិនត្រូវការស្តាប់ពាក្យដំទាស់របស់ឯងទេ ! ឯងជាកូនអញត្រូវតែនៅក្រោមបង្គាប់អញ ! ស្តាប់អញ !

– ក៏ប៉ុន្តែខ្ញុំអត់ស្រឡាញ់គេណា ...! មនុស្សមិនស្រឡាញ់គ្នា ប៉ារៀបការទៅតើវាបានប្រយោជន៍អ្វី ?

អម្ពរឆ្លើយទៅឪពុកព្រមជាមួយគ្នាទឹកភ្នែកនាងក៏ហៀរហូរជោគផ្ទៃមុខ ។

– អារឿងស្រឡាញ់ឬមិនស្រឡាញ់ ដល់រៀបការរួចទៅវាគង់តែស្រឡាញ់គ្នាទេ ! (លោកជង្ហោមានប្រសាសន៍) ឯងប្រកែកដូច្នេះមានតែឯងហ្នឹងលួចស្រឡាញ់ប្រុសផ្សេង ? បើមានស្រឡាញ់អាណាប្រាប់អញភ្លាមមក !

អម្ពរនាងចង់តែស្រែកប្រាប់ឪពុកក្តែងៗ ថា នាងស្រឡាញ់ទិវា តែចិត្តមួយចូលមកបង្អាក់ឲ្យនាងគិតឃើញថា វាដូចជាអាសអាភាសពេកចំពោះចរិយាស្រីវ័យក្រមុំ ។ ម្ល៉ោះហើយ នាងក៏ឆ្លើយដោះសារផ្លូវផ្សេង ៗ ទៅវិញ ៖

– ខ្ញុំឥតមានជាប់ចិត្តស្រឡាញ់ប្រុសណាទេបា ...!
តែខ្ញុំមិនទាន់ចង់មានប្ដី ...!

– ចុះឯងចាំអង្កាល់ ?

លោកស្រីយៀមសួរ ។

– ចាំះ ! ទុកពេលឲ្យខ្ញុំមានឥស្សរភាពបានបីបួនឆ្នាំទៀតទៅម៉ាក់ ...!

– ទេ ! ទេ ! ទេ ! ( លោកស្រីគ្រវីដៃស្រែកភ្ញាក់សម្លេង ) ទុកបីបួនឆ្នាំទៀតហ្នឹង ប្រាកដជាប្រេះទ្រូងអញស្លាប់, អញទទួលពាក្យម៉ត់បត់នឹងគេណាស់ណា !...

– កាលម៉ាក់ទទួលពាក្យនឹងគេ ម៉ាក់មានបានសួរចិត្តខ្ញុំមុនឯណា ?

– យើ ! មីប្រមាត់អណ្ដែត ! ( លោកស្រីស្រែកសន្ធាប់ម្ដងទៀត) ស្អី ! អញធ្វើម៉ែបង្កើតក្បាលនាងឯង សព្វបើរឿងឲ្យមានប្ដីសីចាំបាច់សួរចិត្ត សួរថ្លើមនាងឯងមុនដែរ? បើតចឹងនាងស្រីល្អឯងមិនមកធ្វើម៉ែអញម្ដងវិញទៅ ?

លោកជង្ហើ ឃើញប្រពន្ធរកហារបាន លោកក៏ជឿនក្លែកជាសញ្ញាឲ្យបញ្ចោញគ្រាប់ឥតទៅទៀត ។ ចំណែកលោកតាញហ្វាំខ្ញាំងពីក្នុងប្រអប់ប្រាក់ប្អូនជ្រុង មកញាត់ខ្សៀ ដុតជក់បឺតផ្សែងបង្ហុយ កុយ កុយ ! បែរមុខទៅរកជញ្ជាំង ធ្វើព្រងើយ ។

- ម៉េច ! នាងល្អងឯងព្រមរៀបការតាមអញទុកដាក់ឬមួយក៏ចង់រើសព្រៃរើសប្ដីចិត្តឯង?

លោកស្រីយឿមសួរ កាលបើឃើញអម្ចាស់នៅស្ងាត់ស្ងៀមយូរ ។

នាងកុលាបសួគ៌ាបានអត្ថុយជញ្ជីងគិតរួចជាស្រេច ថាត្រូវតែប្រកែក ។ ក្នុងជីវិតនេះ នាងមិនអាចទទួលបុរសណាមកធ្វើប្ដីក្រៅពីទិវា ទេវបុត្រស្នេហារបស់នាងតែមួយបានជាដាច់ខាត ។

- ម៉ាក់ភាណាកតកូនផង... ! កូនមិនព្រមយកប្ដីទេ សូមម៉ាក់ជូនពាក្យទៅគេវិញចុះ !...

- អ្ហ៎ ! នែ៎ងជាយ៉ាងម៉េច ? មិនព្រមយកប្ដីទេឬ ?
យើ ! មីអម្ពូរ ! មីកំពពកជ្រូកអាចម៍ជន្លេន !

ជាហើយលោកស្រីក៏ស្ទុះទៅចាប់ក្របួចទាញសក់អម្ពូរ មកទះកំផ្លៀងញាប់ដូចគេអេះ ។ នៅមិនទាន់បាត់ក្ដៅ លោកស្រីក៏ដាក់បីបួនដើងបន្ថែមទៀត បណ្ដាលឲ្យនារីកំសត់ដួលបីបួនត្រឡប់ផេកឱបពោះ ស្រែកថ្ងូរដោយសេចក្ដីឈឺចាប់យ៉ាងគួរឲ្យសង្វេគ ។

លោកជន្ទៅឡាច បែរមកមើលបុត្រីហើយងក់ក្បាលញញឹមតិច ៗ លោកពេញចិត្តនឹងការធ្វើទារុណកម្មនេះណាស់ ។

និយាយពីលោកស្រីយឿម កាលបើឈរបាត់ហត់បន្តិចហើយ ក៏ស្ទុះទៅទះតប់កូនបន្ថែមឲ្យដួលស្របប៉ាច រហូតសន្លប់បាត់ស្មារតី ។ កំហឹងលោកស្រីពេលនេះធាបឆេះដល់បន្ទុក លោកស្រីក្ដៅចិត្តណាស់នឹងកូនក្បាលរឹងតឹត ជាសុខចិត្តវាយឲ្យស្លាប់ ល្អជាជាងទុកឲ្យកូនបង្អាប់កិត្តិយស

វង្សត្រកូលដូច្នេះ ។

— យើ ! មីអម្ពរ ! ហ៊ុះ ( លោកស្រីមានប្រសាសន៍បណ្ដើរគន្ធើញផាយសំពត់បណ្ដើរ ) ប៉ះលើម៉ែណាគ្រាន់ហាន ! ប៉ះបំលើម៉ែអញ ហ្អែងកុំមករឹងទទឹងក្បាលចិត្តមិនបានទេ ! អញសុខចិត្តវាយហ្អែងឲ្យស្លាប់ ហើយចាំអញដើរចូលគុកជាក្រោយណា !

អនិច្ចា !... ទោះជាលោកស្រីខំស្រែកជេរទាល់តែជ្រុះក្រទៀត ក៏អម្ពរមិនឮដែរ ព្រោះពេលនេះនារីកំសត់សន្លប់បាត់ស្មារតីទៅហើយ ។

លោកជន្លៅដឹងថាកូនសន្លប់លោកក៏ដើរមកឈ្ងោកមុខបន្តិចរួចទាញដៃប្រពន្ធឲ្យចេញក្រៅ ។

— ប៉ុណ្ណឹងបានហើយម៉ាក់វា !.. ចាំវាដឹងខ្លួនឡើងវិញយើងមកសួរបញ្ជាក់ម្ដងទៀត ។

គួរឲ្យអាសូរអម្ពរណាស់ ! នៅពេលនាងដឹងខ្លួនវិញលោកជន្លៅឡាចនិងលោកស្រីយៀម មកជំរិតសួរបន្ទំចិត្ត

ឲ្យនាងព្រមរៀបការជាមួយកូនកម្លោះ ថៅកែចំការក្រូចអូរដំបងទៀត ។ តែយុវតីកំសត់ នៅតែឆ្លើយបដិសេធដូចមុនដដែល សុខចិត្តឲ្យម្ដាយវាយធ្វើបាបបែកសាច់ហូរឈាមសន្លប់ថប់បួនលើក ។

លោកស្រីយឿម កាលបើវាយធ្វើបាបប៉ុណ្ណឹងហើយនៅមិនបានផល លោកស្រីក៏ឈប់វាយផ្លាស់កម្មវិធីថ្មី គឺប្រើរបៀបបង្អត់បាយបង្អត់ទឹកម្ដង ។

ថ្ងៃនេះពេញមួយថ្ងៃ កញ្ញាកំសត់ឥតបានទទួលទានអាហារអ្វី សំរន់ក្រពះក្រៅពីលេបទឹកមាត់ក្អឿកៗ ។ ដេកថ្ងូរហ៊ុមនៅក្នុងបន្ទប់យ៉ាងទុព្វលភាព ។

រាត្រីនេះ ជារាត្រីខាងរនោច ព្រោះចន្ទពុំបានបញ្ចេញកក្រ្ដមូលក្រឡង់ដូចជារាត្រីខាងខ្នើតទេ ។ យុវតីកំសត់ដេកលើគ្រែថ្ងូរមិនដាច់មាត់គួរឲ្យអាណិត។ ។ សព្វសាពាង្គកាយនាងសុសទៅដោយស្នាមរំពាត់ផ្ដៅ និងស្នាមដំ ។ អាការឈឺចាប់ត្រូវធាតុត្រជាក់ក្នុងពេលរាត្រី ធ្វើឲ្យនាង

កាន់តែទុរន់ទុកស្ទើរផុតជីវិតម្ដងៗ ។

នៅខាងក្រៅផ្ទះ ហ្វូងសត្វរាត្រីចរហិចហើរទៅប្រចឹកផ្លែឈើទុំ ៗ ជាអាហារពីដើមមួយទៅដើមមួយ បញ្ចេញសូរសព្ទរេក ! រ៉ែក ! រេក ! រ៉ែក ! ប្រឡែងលែងនឹងស្រមោលរាត្រីយ៉ាងរីករាយ ៗ អំពិលអំពែក ហើរកាត់ជ្រែកស្បែងងឹត បណ្ដាលឲ្យមានជាកូនពន្លឺតូច ៗ ភ្លឹបភ្លែតៗរួចក៏បាត់សូន្យសុងទៅវិញអស់ក្នុងរយៈពេលដ៏ខ្លី ។

នៅក្រោមផ្ទះ ក្បែរមាត់បង្អួចបន្ទប់អម្ពរគេង ឃើញមានស្រមោលមនុស្សរាត្រី ម្នាក់ឈរមុជងើបៗ នឹងគុម្ពផ្កាបំពុីដូចជាចាំមើលអ្នកណា នៅលើផ្ទះនេះ ។

កន្លះម៉ោងក្រោយមក មនុស្សចម្លែកក៏នៅមិនទាន់ដើរចេញទៅណា គេអុជបារីជក់បឹតបានពីរបីហឺតក៏ស្រាប់តែគ្រវាត់ជាន់ល្វីទឹងជើងបែកផ្កាភ្លើងព្រាត រួចហួចជាទំនុកបទភ្លេងសម័យ ឮគ្រលួចកណ្ដាលរាត្រីស្ងាត់ ។

យុវតីកំសត់ ដេកនៅក្នុងបន្ទប់កំពុងយំសោកអាណិត

ខ្លួន ស្រាប់តែភ្ញាក់ព្រើតនឹងសម្លេងហួច ។ នាងស្គាល់ច្បាស់ សម្លេងហួចនេះមិនមែនអ្នកណាក្រៅពីទិព្វសង្សារកំសត់របស់នាងឡើយ ។

អម្ពរខំប្រឹងខាំមាត់តទប់នឹងសេចក្ដីឈឺចាប់ ក្រោកចុះពីលើគ្រែ ដើរចុចកែងជើងស្រាលៗ លួចបើកទ្វារបន្ទប់ចុះទៅជីជួបប្រុសជីវ៉ា ។

– បងទិព្វឬ ?

អម្ពរនាងសួរកាលបើដើរទៅដល់ជិត ។

ប្រុសកត្រីស្ទុះមកឱបនាងហើយឆ្លើយតបមកវិញ ៖

– បងហ្នឹងហើយអូន !...

– បងទិព្វ...អូន..!

អម្ពរនិយាយបានត្រឹមណោះ ក៏ហាក់ដូចជាមានដុំដែកមួយដុំធំ មករុកស្ទះបំពង់កនាងមិនឲ្យថ្លែងទៅទៀតរួច ។ ទឹកភ្នែកអត្តិពស្រក់តក់ៗ មកលើដៃទិព្វ បង្កើតក្ដីសង្ស័យឲ្យប្រុសកម្លោះជាពន់ប្រមាណ ៖

- ហេតុអ្វីបានជាអូនយំ ? ប្រាប់បងមកមើលអូនអម្ពរយី ! អូនត្រូវអ្នកណាគេវាយដំឬ ?

អម្ពរមិនឆ្លើយតប នាងរឹតតែយំសស្រឹកខ្លាំងជាងមុនលើសដើម ។

ទិវាពេលនេះអ្នកយល់ខ្លះ ៗ ហើយបើទុកជាអម្ពរមិននិយាយប្រាប់ក៏នរៈគាត់ស្មានមិនឲ្យខុសតីសង្សារគេប្រាកដជាត្រូវទទួលទារុណកម្មពីឪពុកម្ដាយនាងប្រាកដណាស់ ។

យុវជន នឹកអាណិតសង្សារស្មើរលេះរលួយ ថ្លើមប្រមាត់ ៗ សេចក្ដីឈឺចាប់ទុក្ខវេទនាគ្រប់បែបយ៉ាង ដែលនាងត្រូវឪពុកម្ដាយធ្វើបាប សុទ្ធសឹងបណ្ដាលមកពីរូបអ្នកមួយជាមូលហេតុ ។ ទិវាហូតក្លូនកន្សែងចេញពីក្នុងហោប៉ៅមកជូតទឹកភ្នែកឲ្យអម្ពរ គេបន្លឺវាចាទាំងអាក់អួលទៅកាន់នាង ៖

- អម្ពរ ! អូនព្រលឹងមាសបងអើយ ...! បើទុកជាអូនមិននិយាយប្រាប់បង គឺបងអាចកាត់ស្មានយល់ដែរ

អូនត្រូវប៉ានិងម៉ាក់អូនលោកវាយធ្វើបាបមែនទេ ?

– ចាំ ! ត្រូវហើយបង ...! ( អម្ពរនិយាយ ) អូនត្រូវប៉ានិងម៉ាក់ធ្វើបាប ព្រោះអូនមិនព្រមរៀបការជាមួយកូនថៅកែចំការក្រូចម្នាក់នៅអូរដំបង...ឥឡូវនេះឪពុកម្ដាយអូនលោកសំរេចឲ្យអូនរៀបការនៅចុងខែខាងមុខនេះហើយ...

– ឱ ! ពុទ្ធោអើយ . . . ជាប់ខែនេះអូនរៀបការ ? ទិវា ឧទានចេញមករបៀបមនុស្សខូចសតិ !

– បើអូនរៀបការហើយ បងក៏មិនខ្ចីនៅរស់ក្នុងលោកដ៏សែនទារុណនេះដែរ ! ជីវិតបងប្រែជាជីវិតគ្មានន័យ រស់នាំឲ្យជំបៅដើមទ្រូងធ្វើអ្វី បើស្រីជាទីស្នេហាបានទៅគេហើយ ! អម្ពរអូន ... បងចង់តែស្លាប់ បងចង់តែស្លាប់ក្នុងពេលឥឡូវនេះទេ ! ជាតិនេះហួសអស់ហើយពិតពិតស្នេហា . . . បងកើតក្នុងត្រកូលអធន ទើបគ្មានវាសនាបេះផ្កាកុលាបសួគ៌ាមកថ្នាក់ថ្នមជាគូជីវិត ...

ថាហើយ បុរសឆ្កួតស្នេហ៍ក៏ក្រញីសក់ខ្លួនឯង សើច

ហះ ! ហះ ! ហះ ! ឮសូរគួរឲ្យខ្លាច ។

អម្ពរ ចាប់ទាញដៃប្រុសសង្សារយកមកថើប ទាំង ពោលពាក្យលួងលោមលើកទឹកចិត្តថា ៖

កុំទាន់អស់សង្ឃឹមបង ! អម្ពរនៅជាអម្ពរសង្សាររបស់បងពិតដដែលទេតើ កុំថាឡើយប៉ាម៉ាក់អូនលោកធ្វើបាបប៉ុណ្ណោះទុកជាលោកធ្វើទារុណកម្មលើសនេះទៅទៀត ក៏អូននៅទ្រាំទ្រនឹងសេចក្តីឈឺចាប់បានជានិច្ច អូនមិនទទួលអ្នកណាធ្វើប្តីក្រៅពីរូបបងមួយទេ !

គាការទុក្ខព្រួយ ហាក់ដូចបានធូរស្រាលពីក្នុងទ្រូងប្រុសកម្លោះមួយគ្រា កាលបើឮសំដីសង្សារគួរជាទីទំនុកទុកចិត្ត ។

– អូនអម្ពរ ! (ទិពនិយាយ) អូនប្រាកដជាមិនព្រមបោះបង់រូបបងទេឬ ?

– ចា៎ះ ! អូនមិនបោះបង់ដរាបជីវិតក្ស័យ !

– បងត្រេកអរណាស់អូន កាលបើបានឮពាក្យដែល

របួតចេញពីមាត់អូនដូច្នេះ  តែកាលណាទៅយើងនឹងបាន

រស់នៅជាប្តីប្រពន្ធពេញលក្ខណៈ ? សង្ឃឹមលើបងចូលស្តី

ដណ្តឹងអូន  បងក៏មានឋានៈតូចតាចក្រៃ ម្យ៉ាងវិញទៀតថ្លៃ

ការក៏កាន់តែខ្ពស់ណាស់ហើយ  តើអូនគិតដោះស្រាយ

ខ្លួនឯងឲ្យរួចផុតពីចំណងអាពាហ៍ពិពាហ៍នេះដូចម្តេច ?

មាណវី  ផុកផង្អើមធំពោរពេញទៅដោយក្តីវិតក្ក ។

នាងគ្មានបញ្ហាទឹងដោះស្រាយវិបត្តិនេះរួចទេ  នាងសង្ឃឹម

ទៅលើឧត្តមគតិរបស់ទិវាតែប៉ុណ្ណោះ ។

- ជួយគិតអូនផង ! (អម្ពរនិយាយមុខស្រងូត) ខួរ

ក្បាលអូនវិលគិតអ្វីលែងឃើញហើយ  យោបល់បងយ៉ាង

ណាអូនសូមតាមបងទាំងអស់...

កាលបើអម្ពរ  ទម្លាក់ភារៈបញ្ហាជីវិតឲ្យអ្នកដោះស្រាយ

ទិវាក៏មានសេចក្តីកង្វល់ចិត្តជាខ្លាំង  ។  អ្នកមិនដឹងដោះ

ស្រាយដូចម្តេចទេ  បើមានស្វាចចេះហោះទៅពាំនាំបងក់

នាំយកទៅទុកឯស្ថានកៃលាស  ឲ្យឆ្ងាយពីស្ថានមនុស្ស

លោកចិត្តមារ  តែបើអ្នកជាមនុស្សប្រុសដូចជានាងដែរ តើឲ្យអ្នកគិតគាបយ៉ាងម៉េចទៅវិញ ?

ខ្យល់ត្រជាក់ពេលរាត្រី  បក់រំភើយៗមកបោកស អង្អែលមិនដាច់រយៈ  តែចំពោះទិវាអ្នកមិនបានត្រជាក់កាយ សោយទុក្ខសូម្បីបន្តិចបន្តួចឡើយ ។ ប្រុសកម្លោះអត្តិយ សញ្ជាប់សញ្ជឹងភ្នែកសម្លឹងមើលទៅហ្វូងតារាតូច ៗ រាយដេរ-ដាសនៅលើមេឃាដោយគ្មានន័យ ។ ខួរក្បាលកំពុងត្រូវដោះស្រាយវិបត្តិស្នេហាពាន់ម៉ឺនជំពូក ។ គិតហើយគិតទៀត ! គិត ! គិត ! ឃើញមានតែផ្លូវម៉្យាងគឺនាំគ្នារត់បើមិនដូច្នោះ  គេនឹងអម្ពរគ្មានវិធីណាដោះស្រាយឲ្យបានស្រួលជាងនេះឡើយ ។

ទិវា  លើកដៃអង្អែលខ្លួនអម្ពរស្រាល ៗ  គេចទ្វារពា ក្រោយពីអត្តិយគិតជាងមួយម៉ោង ៖

– អូនអម្ពរ ! រឿងយើងពិបាកដោះស្រាយណាស់ ! មានតែផ្លូវម៉្យាងទេ . . .

- ធ្វើយ៉ាងម៉េចទៅបង ?

គម្លាប្រញាប់សួរសង្វាតដោយចង់ដឹង ។

ទិព្វនៅស្ងៀម សម្លឹងមើលមុខនាងហាក់ដូចជាចង់រកការពិតគាថិកបាំងនៃដួងចិត្តអ៊ីម៉្យាង ទើបគេឆ្លើយថា៖

- វិធីហ្នឹងវាគាបប៉ះពាល់ផលកិត្តិយស គ្រួសារអូនបន្តិច ... បងដូចជាមិនចង់ហ៊ាននិយាយសោះ

- និយាយមកចុះបង ! ឲ្យតែជាយោបល់បង អូនយល់ព្រមតាមទាំងអស់ !...

- បើអូនចង់បានគ្នាជាប្ដីប្រពន្ធ !... គ្មានវិធីណាដោះស្រាយរួច ក្រៅពីនាំគ្នារត់ទៅនៅខេត្តក្រៅទេអូន ..!

- នាំគ្នារត់ ?

- យុវតីឧទានខ្ទង់ក្រាក់ ៗ បេះដូងនាងលោតញាប់ខុសធម្មតា នាងស្រឡាញ់ឪពុកម្ដាយណាស់ ៗ តាំងពីកើតមក នាងពុំដែលបែកឆ្ងាយចេញពីអ្នកមានគុណនាងទាំងពីរឲ្យបានមួយថ្ងៃទេ ៗ តើពេលនេះនាងត្រូវតាម

ឪពុកម្ដាយឬតាមសង្សារ ? បើតាមសង្សារនោះគាត់ត្រូវខូចកិត្តិយស ៗ ចិត្តនាងកាន់តែមិនដឹងជាប់ចិត្តសំរេចទៅខាងណា ៗ ម្តងចង់តាមឪពុកម្ដាយ ម្តងចង់តាមសង្សារ ៗ គិតឡើងគិតចុះអស់មួយសន្ទុះនាង ក៏សំរេចចិត្តថាត្រូវតាមសង្សារព្រោះសុភមង្គលក្នុងជីវិត ខ្លួននាងជាអ្នកដោះស្រាយ មិនមែនឪពុកម្ដាយដោះស្រាយឯណា ?

កញ្ញាអម្ពរគិតឃើញដូច្នោះហើយ នាងក៏និយាយទៅកាន់សង្សារថា ៖

– បងទិព ...! ពេលនេះអូនសុខចិត្តរត់តាមបង អូន មិនព្រមឲ្យ ប៉ានិង ម៉ាក់រៀបការជាមួយកូនថៅកែបំការគ្រប់ទេ !...

– អូនគិតស្រួលហើយឬ ?

ទិពសួរបញ្ជាក់ ៗ

– ចា៎ ! អូនគិតស្រួលហើយសូមបងកុំធ្វើបាបអូន ទៅថ្ងៃក្រោយណា៎បងណា៎

នាងកុលាបសួគ៌ាទុកចិត្តលើពាក្យសម្បថ របស់ប្រុស សង្ហាអស់ពីពោះពីពុង ៗ នាងក្បត់កិត្តិយស ក្បត់មាតា-បិតាស្អូនឲ្យឈឺង ៗ នាងនៅចាំម៉ានតែម៉្យាងគឺទឹកទេវបុត្រ ស្នេហារបស់នាងមួយប៉ុណ្ណោះ ៗ

ឃើញទេ ? អំណាចស្នេហាកាចសាហាវជាងគ្រាប់បែកប្រល័យលោកហើយធំជាងភ្នំព្រះសុមេរុរាប់ពាន់ដងទៅទៀត ៗ ស្នេហាធ្វើឲ្យមនុស្សឆ្កួត ! ស្នេហាធ្វើឲ្យមនុស្សក្បត់កិត្តិយស ! ក្បត់គ្រួសារ ! ក្បត់ឪពុកម្ដាយ ! គិតទៅស្នេហាជាគ្រាប់បែកប្រល័យអនាគតរបស់មនុស្សលោកដោយសុទ្ធសាធ ៗ តែ . : គួរឲ្យឆ្ងល់ណាស់ ! បើទុកជាមនុស្សដឹងយ៉ាងនេះហើយក៏ដោយ ក៏មនុស្សគ្រប់រូបនៅ តែជក់ខ្លួនបញ្ចូលឲ្យធ្លាយពីអន្ទាក់ស្នេហាចង្រៃនេះមិនរួច ៗ

ព្រឹកស្អែកឡើង នៅផ្ទះលោកជស្ទៅម្ភាប ក៏កើតមានព្រឹត្តិហេតុចង្រៃមួយ បណ្ដាលឲ្យសមាជិកក្នុងគ្រួសារ

ក្បាក់ផ្អើលផ្សួលច្របល់ពេញតែផ្ទះ គឺដំណឹងបាត់នាងអម្ពរ ។ លោកជង្ហោ និងលោកស្រីភរិយាមានសេចក្ដីភិតភ័យនិងខ្មាស់គេមុខខ្មៅដូចមរណ៍ ។ លោកបានចាត់ឲ្យមនុស្សក្នុងផ្ទះ ដើរតាមរកនាងអម្ពរគ្រប់ទីកន្លែងក្រែងនាងនឹកតូចចិត្តនឹងម្ដាយរឿងពីម្សិលមិញ លួចទៅបង្គប់លោតទឹកសម្លាប់ខ្លួន ។ រីឯខ្លួនលោកនិងភរិយាក៏ចូលទៅក្នុងបន្ទប់រុះរើក្រែងនាងលួចមាសពេជ្រអ្វីយកទៅនឹងខ្លួនខ្លះ តែប្រដាប់ប្រដារប្រើប្រាស់គ្រឿងអលង្ការនៅគ្រប់ដដែល ។

ជង្ហោម្នាបឈរគិតមិនលេចឈ្លបមិនចេញ មិនដឹងជាកូនទៅខាងណាមកខាងណា ។ នៅពេលលោករៀបដើរចេញក្រៅវិញទៅហើយ ក៏ស្រាប់តែភ្នែកលោកទៅប្រទះនិងលិខិតមួយសៀតជាប់នឹងក្បាលគ្រែនាងអម្ពរដេក ។

លោកជង្ហោស្ទុះរ៉ុយទៅយកសំបុត្រចម្លែកមកលាតអានទាំងបុកពោះឌឹប ៗ ឌឹប ៗ ដូចគេចូងស្គរ ។ សេចក្ដីក្នុងលិខិតមានសេចក្ដីថា ៖

នៅក្នុងបន្ទប់ដេក ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧២

សូមប៉ានិងម៉ាក់ជ្រាប !...

នៅពេលប៉ានិងម៉ាក់អានលិខិតអក្សរនេះ ខ្ញុំកូនបានឃ្លាតចេញទៅឆ្ងាយហើយ ។

ហេតុដែលបណ្ដាលឲ្យកូនដាច់ចិត្តរត់ចោលប៉ានិង-ម៉ាក់ មកពីកូនមិនពេញចិត្តរៀបការ ជាមួយកូនកម្លោះថៅកែបំការក្រុមនៅអូរដំបង ។ ណាក់ប៉ាំងអ៊ី ប៉ា ! ម៉ាក់ ! ខ្ញុំកូនសព្វថ្ងៃមិនមែនទំនេរទេ កូនមានសង្សាររួចទៅហើយ តែសង្សាររបស់កូនគ្មានអក្សរណាស់ គ្នាកើតមកក្នុងត្រកូលអ្នកក្រីក្រ ។ ដូច្នេះបើទុកជាគ្នាចូលស្ដីដណ្ដឹងត្រឹមត្រូវតាមផ្លូវច្បាប់ក៏គង់តែប៉ានិងម៉ាក់មិនយល់ព្រមដែរ ។

ហេតុនេះ បានជាកូននឹងគេសុខចិត្តបបួលគ្នារត់ចេញពីផ្ទះទៅ ទាំងអធ្រាត្រស្ងាត់ ទោះជាដឹងថាខុសនឹងប្រពៃណីជាតិក៏ដោយ ។ ប៉ានិងម៉ាក់ ! គិតថាកូនស្រីរបស់ប៉ាម៉ាក់ ! ស្លាប់បាត់ពីលោកនេះចុះ ។ បើថ្ងៃណាទេវតាសល្អកូន គង់មានសំណាងបានវិលមកជួបប៉ាម៉ាក់វិញពុំខាន ។

ពីកូនស្រីក្បួចប្រពៃណី

**ឡឹក·អម្ពរ**

អានលិខិតកូនក្រមុំចប់កាលណា ជស្តៅឡាបគំ ក្រេវក្រោធទឹកក្ដៅចិត្តមុខឡើងក្រហមឆាំងដូចភ្លើង ៗ លោកស្រែកគំហកខ្លាំង ៗ ដូចខ្លាត្រូវបួសរបស់នាយព្រានព្រៃថា៖

– ហើ ! មីអម្ពរ ! មីកូនលក់កិត្តិយស ឪ! ឯងខំរកប្ដី ឲ្យវាអ្នកមានមុខអ្នកមានមាត់ ប្រយោជន៍ឲ្យវាបានថ្កុំថ្កើង ! ត្រឡប់ជាវាបែររត់តាមប្រុសឈ្មោល ទាំងកណ្ដាលអធ្រាត្រ ទៅវិញ អញក្ដៅណាស់ ! ពីថ្ងៃនេះទៅហាងនិងអញត្រូវ ទុកជាសត្រូវគ្នាទល់ថ្ងៃស្លាប់ ! អញជួបហាងកន្លែងណា អញការកហុតឈាមហាងកន្លែងហ្នឹង !

– វាសរសេរដាក់ថាយ៉ាងម៉េចប៉ាវ៉ា ?

លោកស្រីយឿមសួរដោយងឿងឆ្ងល់ ព្រោះមិនទាន់បានអានសេចក្ដីសំបុត្រ ។

— ថាសរសេរយ៉ាំងម៉េច ! វាសរសេរថាវាតែតាមប្រុសណា ! បើឯងចង់ដឹងមើលសំបុត្រវាទៅ !

ថាហើយលោកជង្ហៀឡាច ក៏គ្រវាត់សំបុត្រទៅឱ្យភរិយា ។ ដើរចេញមកខាងក្រៅទាំងអារម្មណ៍ក្រេវក្រោធ ។

លោកស្រីយឿមអានសំបុត្រអម្ពរបល់ ក៏ដកដង្ហើមធំវែងអាត់វែងត ។ ដើរចេញទៅរានហាលមុខផ្ទះអង្គុយបៀមម្លូស៊ីធ្មេញក្ដុកក្ដុះៗ ដោយនឹកហួសចិត្ត ។

ហ្នឹងហើយអស់លោកអ្នកអានជាទីមេត្រី ! កូនស្រីសម័យឥឡូវ ពិបាកស្ដីប្រដៅខ្លួនណាស់ ។ តែឪពុកម្ដាយមិនយល់ចិត្តកូនធ្វើខុសរបៀបបន្តិច មុខជាវាយកែងជូនលោក ដូចកញ្ញាអម្ពរកុលាបស្លូតាផែនដីស្រុកមោងឫស្សីផបឹង !



ម៉ៅ-គុសុមោ
Kusumo MAO

# ៣

ព្រោះស្រឡាញ់បានផាត់តាម

ព្រោះស្រីស្រឡាញ់ ស្រឡាញ់ស្មោះ
ម្តូររត់តាមប្រុស ប្រុសសង្ស័យ
បានកាយចង់ណាយ ណាយចិត្តា
សម្បថមុសា មុសាស្រី ។

ទិវ៉ានិងអម្ពរ នាំគ្នារត់មកភ្នំពេញ ហើយជួលកូនផ្ទះតូចមួយ នៅល្មមពីរនាក់ប្តីប្រពន្ធ នៅខាងក្រោយវត្តលង្កា ។

ទិវ៉ាចំប្រឹងស្វាគមន៍ស្វែងរកការធ្វើចំនួនមួយអាទិត្យ គេក៏បានការធ្វើនៅកន្លែងពេទ្យពុម្ព ។ យុវស្វាមីករិយាភត

ខាន់ស្លាគូនេះស្រឡាញ់គ្នាណាស់ គេមិនដែលបង្ករហេតុអ្វីឲ្យទុស្ដាន រវាងគ្នានិងគ្នាឡើយៗ ទំរាំដល់ពេលចុះពីធ្វើការ គេក៏ត្រឡប់មកផ្ទះភ្លាម ចំណែកអម្ពរវិញ នាងខំតាំងខ្លួនធ្វើមេផ្ទះដ៏ប្រសើរបំរើផ្គាប់ផ្គុនយកចិត្តយកថ្លើមប្ដីមិនឲ្យមានទាស់ៗ

ដោយការប៉ិនប្រសប់ រៀបចំទុកដាក់ថ្នាក់ថ្នម របស់អម្ពរកូនផ្ទះតូចនេះ ក៏ក្លាយទៅជាវិមានសួគ៌យ៉ាងសែនសុខ ៗ ម៉្យាង នៅពេលដែលប្ដីប្រពន្ធក្មេងនេះជួបជុំគ្នា គេឮស្នូរតែអូន ! បង ! សើចក្អាកក្អាយសប្បាយរីករាយ មិនដាច់ពីមាត់ ៗ

– បងអា៎...! ស្អែកពេលបងត្រឡប់មកពីធ្វើការ បងទិញនំបុ័ងខ្សែក្រើងមកញ៉ាំសម្លការីណា៎បងណា៎ ...!

– អូនកុំព្រួយ ! ចាំស្អែកបងទិញយកមក ! អូននៅផ្ទះកុំដើរលេងផ្ទះគេរហេតរហូតឮទេ ? ដាច់ខែនេះបងបើកប្រាក់ខែមក ចាំបងជូនអូនទៅទិញសំពត់ការទិនបំភ្លៀនរូបពស់ឲ្យអូនមួយផង !

មែនឬបង ? បងកុំកុហកអូនណា៎ ... ខំអូនខឹងបងឯងហើយហ៊ឹះ !...

— បងមិនកុហកអូនទេ ...! បងបានស្បថឲ្យឡានបុក បើសិនជាបងនិយាយមិនពិត

— ស្អប់ណាស់បង...! បាននិយាយស្អីឡើងគាន់តែស្បថ !...

— ចុះបើបងមិនស្បថ ធ្វើម្ដេចអូនចិងជឿចិត្តបង ?

មួយឆ្នាំកន្លងផុតទៅ ពាក្យអូនពាក្យបងក្នុងកូនផ្ទះតូច ដែលទិភានិងអម្ពរយកធ្វើជាវិមានសួគ៌ដោយសន្មត កំប្ដើមបាត់អស់ទៅវិញម្ដងបន្តិចៗ ដូចស្លឹកឈើជ្រុះពាកមែកក្នុងហេមន្តរដូវ ។

ឥឡូវនេះ ទិភាចេះប្រើសំដីធ្ងន់ទ្រគោះភោះបោកឲ្យអម្ពរ ៗ គេដើរលេងផឹកស៊ីស្រវឹងប៉ោវែង ជួនកាលមានដើរបាត់ពីផ្ទះពីរបីយប់ ៗ ដល់ត្រឡប់មកផ្ទះវិញអម្ពរស្ទើរដេញដោល ក៏បង្កើតមានមាត់កឈ្លោះប្រកែកគ្នាឡើង

រហូតដល់ទៅតមសំដីលែងនិយាយរកគ្នារាប់អាទិត្យ ។

សព្វថ្ងៃទិពកំពុងបាក់ចិត្តស្រឡាញ់នារីមេម៉ាយ ប្ដីលែងម្នាក់នៅផ្សារដេប៉ូ ។ ប្រាក់ខែបើកមកបានប៉ុន្មាន ប្រគល់ឲ្យនាងមេម៉ាយទាំងអស់ ។ គេភ្លេចពាក្យស្បថ ភ្លេចអម្ពរជាប្រពន្ធកំសត់គេអស់ហើយ ។

ថ្ងៃនេះទិពចុះពីធ្វើការ គេមិនទៅផ្ទះគេឯក្រោយវត្តលង្កាទេ គេត្រឡប់ជាជិះសូឡិចទៅផ្ទះនាងមេម៉ាយស្រីកំណាន់នៅផ្សារដេប៉ូទៅវិញ ។

នាងសោភា មេម៉ាយ សាច់ខ្ចីល្អក់ដូចបណ្ដូលចេក គ្រាន់តែឮសូរសូឡិចទិពមក ក៏ស្ទុះចេញទៅទទួលដល់មាត់ជណ្ដើរផ្ទះ ។

— អូនស្មានតែបងមិនអញ្ជើញមក ឲ្យអូនធ្វើបាយខកមុខជាកើតរឿងធំហើយ !...

នាងសោភានិយាយវៀចមាត់វៀចក ប្រកបទៅដោយមាយាជគគិ ។ ទិពចាក់សោរសូឡិចស្រួលបួលហើយ ក៏

កាន់ដៃស្រីកំណាន់ឡើងទៅលើផ្ទះ ។

- បងតែចាំមកគឺស្រាកដជាមកហើយបង តាំងពីកើតពោះម៉ែមក មិនដែលនិយាយកុហកអ្នកណាបានម្ដងទេបើអូនមិនជឿ ! បងសូមស្បថជូនអូនឲ្យស្លាប់តែហឹតតែហោងទៅចុះ !...

- ចុះមានអ្នកណាគេថាមិនជឿ ? ស្អប់ណាស់បងទិព ! និយាយដប់មាត់ស្បថអស់ប្រាំបួនមាត់ហើយ ប្រយ័ត្នទាញពាក្យស្បថស្លាប់ខ្លួនណា៎ !...

ទិពគ្រវីក្បាលពេបមាត់

- បងមិនខ្លាចស្លាប់ទេ ! បើបងមិនស្បថ តើម្ដេចអូននឹងជឿ ?

សោភាស្រីមាយាឥតខ្ចី ដោះតាវ ដោះខោ ដោះស្បែកជើង ស្រោមជើង ឲ្យទិពហើយ នាងគំរត់ទៅយកសារុងពុម្ពមកឲ្យផ្លាស់ ។ ទាញដៃបុរសចិនស្បថទៅអង្គុយលើគ្រែពូក ព្រើមសួរថា ៖

- បងប្រាប់អូនថាថ្ងៃនេះទិញចិញ្ចៀនមួយវង់ មកឲ្យ តើឥឡូវបងទិញមកហើយនៅ ?

- អ៊ូ ! បងទិញមកហើយអូន ! នៅក្នុងហោប៉ៅខោឯណោះ ...

ទិភានិយាយព្រមទាំងដៃចង្អុលទៅរកខោ ។

សោភាទឹកត្រេកអរ ស្ទុះបង់ប៉ាក់ទៅលូកយកប្រអប់ចិញ្ចៀនក្នុងហោប៉ៅខោមកបើកមើល ។

- យើ ! ចិញ្ចៀននេះស្អាតណាស់បង !

- ចុះទិញឲ្យប្រពន្ធសម្លាញ់ចិត្តហើយទៅឲ្យគន់យ៉ាងម៉េចនឹងកើត !

ថាហើយ ទិភាក៏លើកចិញ្ចៀនស៊កទៅក្នុងម្រាមដៃសោភា ។

នាងមេម៉ាយ លើកដៃផ្ទៀងផ្អងមើលចុះមើលឡើងយ៉ាងពេញចិត្ត ។ ឆ្លៀតឱកាសសោភាកំពុងផ្ទួតមិនលំអចិញ្ចៀនទិភាក៏ឱនមុខទៅថើបស្រង់ក្លិនថ្ពាល់គស់ប្អូនថ្មីៗ

ស្រីមាយាធ្វើមុខអៀនប្រៀន ច្រានទ្រូងប្រុសពាលចេញ ៗ និយាយចេញសម្លេងរបៀបក្មេងទើបនឹងផុះឡើងថា ៖

– អុប់បនឹងទិកណាស់ ! ចេះតែលួចមកអ៊ួបគេ ! ជើមើតែជីគេអ៊ុចឹងហ៊ុះ ! អស់ទៀនពាល់គេអស់អាលីង ! ផ្ទើកោយញ៉មតាប់ផាគហើយ

ទិពធានព្លុសោភានិយាយ បញ្ចេញខ្យល់មាយាឲ្យស្តាប់ក៏សប្បាយចិត្តសើចក្អៀកៗ គាប់គកាប់ស្រន់ ៗ

– បើបងមិនមែនប្តីអូនឯង តើអ្នកណាប្តីអូនឯងទៅវិញ? ឥឡូវបងផាកប្អូ? ណែស ថើបបងវិញមកឲ្យករួចគ្នា ...!

និយាយរួចប្រុសងប់កាមកិលេសក៏ចំប៉ាន់ថ្ពាល់ទៅឲ្យសោភាថើប ។ សោភានាងមិនព្រមថើបត្រឡប់ជាជូនរង្វេន់មួយកំផ្លៀងសងវិញលាន់ស្នូរប៉ាច ...!

– អែយួយ អ៊ុយ យី អូនម៉េចក៏វាយធ្វើបាបប្តីឯងឥចឹង ?

- ចាំ នេះអូនរំលឹកបង ក្រោយ ៗ កុំឲ្យប៉ុនល្បួច ឆក់ដូចក្មេងឆក់ហោប៉ៅមុខរោងកុនឥឡឹងទៀត ...

ទិពយកដៃអង្អែលថ្ពាល់ផ្ញើមុខស្ញូញ សួរទៅសោភាថា ៖

- អូនឯងមិនស្រឡាញ់បងទេឬ បានជាចូលចិត្តលេងឈើៗ របៀបនេះហ្នឹង ?

សោភាញញឹម

- ចាំ ស្រឡាញ់ដែរ តែខ្លាចប៉ះចំទៅលើប្ដីគេ ?

- បងនៅកម្លោះបែស មិនដែលមានប្រពន្ធម្ដងណាទេ បើបងមានប្រពន្ធ ស្មានតែដាច់ខែឡើងយកប្រាក់ខែមកឲ្យអូនឯងទាំងអស់ឥឡឹងបានឬ ? បើនៅមិនអស់សង្ស័យ បងសូមស្បថឲ្យឡានបុក

- ល្ហីយធ្ងន់ណាស់ ( សោភាយកដៃចុករន្ធត្រចៀក និយាយទៅនិយាយមកធ្លាក់តែលើស្បថ ខ្ញុំសួររឿងឯងដូចជាតោតទៅចុះបើនិយាយកុំឲ្យចាំបាច់មានស្បថបានទេ ៗ

ទិព្វសើចមាត់ស្មេញស្រទន់គៀន ។ នាយខំប្រឹងនិយាយខ្ទប់ថា ៖

— មនុស្សបង មនុស្សត្រង់ណាស់អូន ... និយាយគឺមិនបានស្បថ ខ្លាចតែគេមិនជឿចិត្ត ?

— តែបើស្បថច្រើនពេក ក៏គេមិនជឿដែរ

សោភាធ្មៀតសើចបន្ថែមកន្ទុយពាក្យមួយផ្លូវទៀត ។

ពេលវេលាកន្លងទៅមុខផាដកាប ។ ទិព្វនិងនាងសោភាមេម៉ាយ ក៏ស្រឡាញ់ស្មោះស្ម័គ្រនិងគ្នា កាន់តែខ្ជាប់ខ្ជួនខ្លាំងឡើង ៗ ។ បុរសឈ្លក់ទឹកកាម មកដេកទៅជាមួយស្រីកំណាន់ឯផ្ទះផ្សារដេប៉ូ ម្ដងបីយប់ឬបួនយប់ទើបគេទៅគេងផ្ទះមួយក្លូត ។ ដល់យូរ ៗ ទៅ រហូតមួយអាទិត្យទៅផ្ទះម្ដងក៏មានដែរ ។ បំណងស្នេហ៍គេនិងអម្ពរសាបរលាបគស់រលីង ។ គេធ្វើមទៀយណាយអម្ពរហើយព្យាយាមរករឿងបង្ករហេតុ ឲ្យមានការពាស់ទែងខ្វែងគំនិតគ្នាជានិច្ចជាកាល

និយាយពីអម្ពរកូនជម្ទាវឡាចវិញ នាងជានារីចិត្តស្លូត គួរឲ្យកោតសរសើរណាស់ ទោះជាប្តីដើរលេងរហោតរហូត ក្រេបផ្ទះក្រេបសម្បែង ក្រេបទាំងរូបនាងទៅទៀត នាងក៏នៅប្រណិបត្តន៍ គោរពកោតខ្លាចប្តីមិនឲ្យធ្វេស ។ នាងទ្រាំធ្វើគធ្វើថ្លង់លេបគ្រួសលេបថ្ម តទប់នឹងអំពើគំរាមកំហែងធ្វើបាបនាងបានជានិច្ច ។ នាងស៊ូតែពីដេកសំរក់ទឹកភ្នែកមិនបញ្ចេញស្តី ព្រោះនាងយល់ថានាងស្រឡាញ់គេ នាងសុខចិត្តកាត់កេរ្តិ៍ខ្មាសរត់ចោលឪពុកម្តាយ មកតាមគេជ្រុលខ្លួនប៉ុណ្ណោះហើយ នាងត្រូវបេះអត់ធ្មត់តស៊ូទៅទៀត ដើម្បីសេចក្តីសុខក្នុងគ្រួសារ ។

ថ្ងៃនេះជាថ្ងៃដាច់ខែ ទិវាបុរសចោលម្យៀតមារយាទថោក ផឹកស្រាស្រវឹងស្អូរប្រខ្លូរ រហូតដល់ម៉ោងបីអធ្រាត្រទើបឃើញលេចក្បាលទៅដល់ផ្ទះ ។

អម្ពរឮស្នូរប្តីគោះទ្វារ ក៏ប្រញាប់ក្រោកទាំងមីងមាំង

មកបើកទ្វារឲ្យ ។ ទិពដើរទ្រេតទ្រោតទៅដួលលើគ្រែ។ ដេកសន្ធឹងសន្ធៃ ហាមាត់ស្អុយស្រោគគ្រុក និយាយគ្រដួរ តុងប្រមុះថា ៖

– មានដាំបាយទុកឲ្យអញស៊ី ...ទេ... ហ្នឹង...ហា...

អម្ពរ ៖

– ចា៎ះ! មានបង ... បងផ្លាស់ខោអាវសិនទៅ ចាំអូនរៀបជូន !....

– ថាហើយ អម្ពរក៏យកសារុងមកឲ្យប្ដីផ្លាស់ រួចប្រញាប់ប្រញាល់រៀបចំទាំងកណ្ដាលអធ្រាត្រ ឲ្យទិពឥតបង្អង់ ។

– អញ្ជើញក្រោកឡើងពិសារបាយបង ! អូនរៀបជូនហើយ...!

ទិពងក់ក្បាលមិនឆ្លើយតប ។ គេក្រោកដើរទ្រេតទ្រោតទៅកាន់តុអាហារទាំងភ្នែកមមីរកបើកស្ទើរមិនរួច ។

ផនពាលក្រឡេកឃើញបាយកក និងម្ហូបត្រជាក់ពីរបីមុខ កើតក្ដីក្ដៅក្រហាយមិនពេញចិត្ត ក៏ស្ទុះក្រោកធាក់តុរលំ ៗ កំពប់បាយសម្ល បែកចានលាន់ឮង ! ធាង ! ខែវមកសម្លក់ប្រពន្ធ ដោយកំហេលក្ដួតកូលថា ៖

- មីអម្ពរ ! មីចោរអន្ទរធាន ! អញឃ្លានបាយចង់ស្លាប់ ! ឯងទៅយកបាយកក សម្លត្រជាក់ពីក្បាលល្ងាចមកឲ្យអញស៊ី ! ឯងធ្វើបៀបហ្នឹងឯងចង់យ៉ាងម៉េច ? ហ្អា ? ជួយស្ដាប់ផងចុះ ! ទេវតាទាំងប្រាំមុឺនលោកធាតុអើយ ! ដើរកាន់អាទិត្យចូលផ្ទះម្ដង ប្រពន្ធនៅមានបាយរៀបចំឲ្យ ហើយហ៊ានតែរករឿងបាយសម្លត្រជាក់ក្ដៅទៀត ៗ តើពាក់កណ្ដាលអធ្រាត្រទៅហើយ អ្នកណាគេនឹងដឹងខ្លួនមក ? តើអ្នកណាគេនឹងអង្គុយកំដៅបាយ កំដៅសម្លទុកឲ្យខ្លួន ?

ឃើញប្រពន្ធស្ងាត់ស្ងៀមមិនបញ្ចេញស្ដីក៏តាំងដំឡើងធ្ងន់

ដូចត្រីគក្ដុះស្រែករូសក៏សបន្ថែមទៀត ៖

- មើល ! និយាយប្រាប់គញូមកមើលមីអម្ពរ ! ម៉េច ក៏បានជាហាងឲ្យគញូស៊ីបាយសម្លត្រជាក់ ! ហើយម្ហូបរបៀប ខ្ញុំគេអីចឹង • ?

អម្ពរ ស្រក់ទឹកភ្នែកតក់ៗ សែនចុកចាប់ ៗ ពាក្យ ហងពាក្យមី ធ្វើឲ្យនាងរន្ធត់ក្នុងចិត្តជាក្រៃលែង ៗ ទ្រាំ សៀមធ្វើគធ្វើថ្លង់ទៅទៀតលែងកើត នាងក៏និយាយឆ្លើយ មកប្ដីមារយាទថ្លៃតៀវិញថា ៖

- បងទិក ! សូមបងអាសូរដល់ទ្រូងខ្ញុំផង ! បង ដើរបាត់ពីផ្ទះប្អូនដប់យប់អើតមុខមកម្ដង ខ្ញុំនៅមានទុកបាយ ជូនបងពិសារកប់ថាខ្ញុំ ស្រឡាញ់ប្ដីណាស់ទៅហើយ ! កណ្ដាល អធ្រាត្រម៉ោងពីរម៉ោងបីផ្ទុះច្បះ បងឲ្យខ្ញុំទៅរកភ្លើង មកកំដៅបាយសម្ល ឲ្យក្ដៅហុយ ៗ ដូចជាផ្ទះហាងយ៉ាង ម៉េចនឹងកើត ? រីឯបងពោលពាក្យ ថាសម្លដូចជាសម្លខ្ញុំ

គេ គឺវាមិនត្រូវដែរ ប្រាក់ខែប្រាំមួយប្រាំពីរខែមក
ហើយមិនដែលឱ្យខ្ញុំមួយជ្រុងសេនសោះ ខ្ញុំខំបញ្ចាំសំពត់
បញ្ចាំអាវ ដើរលក់ឆ្នោតជាតិត្រឹមៗដូចឆ្កែដំបៅក្បាល ចូល
គ្រប់ច្រកគ្រប់ល្ហក ! ធ្វើម៉េចនឹងបានប្រាក់ឯណាច្រើនធ្វើ
ម្ហូបឱ្យវាឆ្ញាញ់ពិសារ ?

និយាយរួច នាងក៏យំសសឹកទឹកតូចចិត្តនឹងវាសនា
ដែលបានឱ្យនាងគពប្រសប់តែស្រមោលទុក្ខក្នុងជីវិត ។

ឯវាមិនព្រមភ្ញាក់កំណើតទេ គេត្រឡប់ជាឆ្លើយយក
ត្រូវម្នាក់ឯងថា ៖

– ហ្អែងឯងសត្វថ្ងៃវាតែប៉ុណ្ណឹង ! រស់ដេកបំពារមាត់
ចាំស៊ីលើកម្លាំងអញម្នាក់ ! អញឯណោះខំប្រឹងរកស៊ីញើស
ហូរជាទឹក បើអញមិនឱ្យលុយហ្អែង ហ្អែងក៏មិនឱ្យបាយអញ
ស៊ីដែរ ចេះមួងៗ ហ្អែងមិនធ្វើម៉ែអញវិញទៅ ?

– មានប្រសាសន៍ ឱ្យបានពិរោះស្ដាប់ជាងនេះបន្តិច

ទៅបង ខ្ញុំមិនចង់តមាត់ តកឲ្យលេចឮផ្ទះពីរផ្ទះបី ពាក់កណ្ដាលអធ្រាត្រឥចឹងទេ ! បងឥឡូវខុសពីមុនឆ្ងាយណាស់ ! ខ្ញុំកាត់កេរ្ដិ៍ខ្មាស់រត់តាមបង ព្រោះសង្ឃឹមថាបងស្រឡាញ់ខ្ញុំដោយសុទ្ធចិត្ត ! ពេលនេះបងភ្លេចអស់ហើយពាក្យស្បថមែនទេ ?

– កាលដែលអញស្បថ អញស្មានតែឯងស្រឡាញ់អញរះហួតដែរ ?

ទិវាស្រែកលៀនសារសេក ៗ

– ចុះពេលនេះអ្នកណាក្បត់អ្នកណា ? ក្រែងបងទេឬ ក្បត់ចិត្តខ្ញុំទៅមានស្រីថ្មីទៀត ? បងល្បក់វង្វេងនឹងមីស្រីចិត្ដោមថ្នល់ ក្មេងប្រពន្ធកំសត់ ! ហ្នឹងហើយឬសេចក្ដីស្មោះត្រង់របស់បងឯងចំពោះខ្ញុំ ?

ផុតគន្លុយពាក្យស្ដីរមិនទាន់ ទិវាក៏ស្ទុះទៅដាល់ចំ-កណ្ដាលមុខអម្ពរពីរបីដៃផាច់ ! ផាច់ ! ហើយក៏ធាក់នាង

ថុំង! ដួលត្រឡប់ត្រឡិនទៅគៀនជញ្ជាំង ។

លោហិតស្រស់ ៗ ហូរចេញពីមាត់ពីច្រមុះនារីកំសត់ ប្រឡាក់ពេញផ្ទៃមុខគួរឲ្យអាណិត តែចំពោះបុរសចិត្តជាតិរច្ឆានដូចទិវាគេគ្មានអាណិតនាង គេក្ដៅចិត្តណាស់ ដែលនាងហ៊ានពោលពាក្យត្មះតិះដៀលថា សោភានារីតំពូលដួងចិត្តរបស់គេជាស្រីចិញ្ចឹមថ្នល់ៗ

– នេះអញសូមប្រដៅឯង ថ្ងៃក្រោយកុំឲ្យនិយាយរបៀបហ្នឹងទៀត! ( ទិវាឈរនិយាយចង្អុលមុខអម្ពរ ) ឯងគិតធ្វើយ៉ាងម៉េចឲ្យតែខ្លួនឯងល្អប្រសើរម្នាក់ឯងទៅបានហើយ ឯងមិនចាំបាច់ដៀមដាមរាលដាលទៅដល់គេទេ!

អម្ពរនាងខ្ទួតចិត្តខ្ទឹតខ្ទាំ ៗ ទឹកភ្នែកហូរច្រណាំង និងឈាមស្រស់ៗ គ្មានស្រាកស្រាន្ត ៗ ពេលនេះទើបនាងដឹងថាខ្លួននាងខុស ៗ នាងបាញ់ពាក្យប្រុសអប្រិយ៍ ៗ នាងចេះនឹកឪពុកម្ដាយ ចេះសោកស្ដាយវ័យក្រមុំព្រហ្មចារីយ៍

ដែលមិនគួរណាយកមកតបនឹងលើប្រុសយ៉ាងនិងវា ៗ តែគ្រប់យ៉ាងវាគ្រាន់តែជាវិប្បដិសារីប៉ុណ្ណោះ ព្រោះគ្រូៗ ដែលនាងសោកស្ដាយក្នុងជីវិត វាបានវិលផុតហួសអស់ទៅហើយក្នុងជាតិនេះ ៗ

នាមដើម ម៉ៅ_កុសុមោ
ម៉ៅ_រ៉េម៉ុង
Raymond MAO
Kusumo MAO

## ៤

### កាត់ចិត្តឥតអាសូរ

កាត់ចិត្តចាកចោល ចោលពុំងារ
ឲ្យរងវេទនា វេទនាប្រាណ
បំភ្លេចក្ដីស្នេហ៍ ស្នេហ៍កល្យាណ
ចិត្តប្រុសតិរិច្ឆាន តិរិច្ឆានណោ !

ចាប់តាំងពីយប់វាយធ្វើបាបនាងអម្ពរមក ព្រឹកស្អែកឡើងទិវាក៏ដើរបាត់ពីផ្ទះ លែងឃើញលេចមុខមកទៀត ។

ការពិតអម្ពរនាងមិនដាច់អាល័យ ពីទិវាទេ ទោះជាទិវាធ្វើបាបវាយដំប្រាំដាក់ ឲ្យនាងទទួលសេចក្តីឈឺចាប់យ៉ាងនេះហើយក៏ដោយ នាងនៅតែនឹកគេហើយស្រឡាញ់គេដាច់ជានិច្ច ។

មួយអាទិត្យ ..មួយខែ.. ពីរខែ...បីខែ...បានកន្លងផុតទៅ ទិវាក៏នៅតែមិនទាន់ឃើញចូលផ្ទះ ។ ទុក្ខសោកកេតព្រួយ ចូលមកជះជាន់ក្នុងដួងចិត្តអម្ពរនារីកំសត់ទ្វេឡើង ៗ ជាលំដាប់ ។

ល្ងាចនេះ ខណៈដែលអម្ពរ អង្គុយសំកុកសំរក់ទឹកភ្នែកនឹកអាណិតខ្លួន ក៏ស្រាប់តែឃើញទិវាជិះស៊ីក្លូមកឈប់មុខផ្ទះ បាត់ឯស្លូឡើប ។ នារីរងកម្មស្ទុះចុះទៅទទួលដំណើរប្តី ដោយសេចក្តីត្រេកអរ តែទិវាត្រឡប់ជាធ្វើមិន

ឃើញ នាងដើរឡើងទៅលើផ្ទះបាត់ទៅ ។ ភរិយាក៏សត់ស្លុតចិត្ត ដើរឡើងតាមក្រោយប្តីទាំងសុបសៅ ។

ទិភ ដើរចូលទៅក្នុងបន្ទប់ រើកកាយខោអាវ ប្រដាប់ប្រដារប្រើប្រាស់របស់គេទាំងប៉ុន្មាន ញាត់ចូលក្នុងវ៉ាលិស ហើយលើកកាន់យួរប្រុងចុះទៅដីវិញ ។ តែពេលនោះ អម្ពរចាប់កដៃជាប់ ។ នាងសួរប្តីក្សបដោយសម្លេងគួរឲ្យអាណិតថា ៖

– បងគិតទៅណាទៀត ? បងចង់រត់ចោលប្រពន្ធកំសត់ឬ ?

– ទេ ! យើងអស់ប្តីអស់ប្រពន្ធគ្នាត្រឹមហ្នឹងហើយ !.. ខ្ញុំត្រូវការបែកផ្លូវដើរជាមួយនាង !

ទិភមុខក្រញូវ និយាយសម្លេងកំបុតកំបុយ ។

ទឹកភ្នែកអក័ព្ទស្រក់ព្រូ ពាសពេញវង់ភ័ក្ត្រនារីមួយរំពេច ។ អម្ពរសំរូតកាយលើកដៃសំពះទាបបាទជើងទិភ ។

នាងពោលរាំពាទឹកភ្នែកដោយរអាក់រអួលទៅកាន់គេ ៖

– បងទិវាចាះ ? សូមបងអាសូរប្រពន្ធផង...ប្រពន្ធសូមក្រាបសំពះបាទជើងបងហើយ បងជាស្នេហ៍ប្រចាំជីវិតរបស់អូន... បើបងរត់ចោលអូនឲ្យនៅស្រុកគេម្នាក់ឯងដូច្នេះតើអូនមានទំពឹងសង្ឃឹមទៅលើអ្នកណាទៀត...

អស់ពីសំពះប្រពន្ធកំសត់ក៏ឲបជើងប្ដីជាប់

–ប្ដីសម្លាញ់... ! អូនកាត់ចិត្តចុះចេញពីផ្ទះទាំងកណ្ដាលរាត្រី...ចាកចោលឪពុកម្ដាយមកតាមបង សង្ឃឹមរស់នៅក្នុងភាពជាប្ដីប្រពន្ធកំសត់ជាមួយគ្នា រហូតអស់ជីវិតរៀង ៗខ្លួន...! ចុះពេលនេះ... ខ្មោចព្រាយបីសាចអ្វីចូលមកសណ្ឋិតក្នុងដួងចិត្តរបស់បង បានជាបណ្ដាលឲ្យបងដាច់ក្ដីអម្ពរ...ដែលបងធ្លាប់ស្បថសច្ចា ចំពោះដួងតារាយពាន់ ជានិងស្រឡាញ់ទល់ជីវិតក្ស័យហើយឬ ?

– នាងកុំយករឿងអតីតកាល មកនិយាយជាមួយខ្ញុំ

ទៀត, ទិពនិយាយធ្វើមុខព្រឹង, ភ្នែករបស់នាងនិងខ្ញុំ ក៏គ្រាន់តែជាធាកណ្ហានកំសត់ ក្នុងចំណោមភ្នែកកំសត់នានាមួយប៉ុណ្ណោះ !

– បងទិព ! ( អម្ពរឧទាន ) ម្តេចក៏បងមានប្រសាសន៍ឥចឹងទៅវិញ ? បងមិនមែនជាបងទិពដែលខ្ញុំធ្លាប់ស្រឡាញ់ទេឬ ?

– ត្រូវហើយ ! ខ្ញុំមិនមែនទិពដែលនាងធ្លាប់ស្គាល់ ធ្លាប់ស្រឡាញ់ទេ ! ខ្ញុំជាទិពថ្មីម្នាក់ទៀតដែលនាងត្រូវតែស្អប់...ហើយបើនាងមិនស្អប់ខ្ញុំ ! ខ្ញុំក៏ស្អប់នាងដែរ...

ឈប់ស្ងៀមបន្តិច ទិពឬប្រុសអប្រីយ៍ក៏មានវាចាឡើងទៀត ៖

–យើងអស់កិច្ចការនិងពិភាក្សាគ្នាហើយសូមនាងលែងជើងខ្ញុំឲ្យមានឥស្សរភាពផង ...

ថាហើយ ទិពក៏ឈានជើងដើរទៅមុនតែទៅមិនរួច

ដោយអម្ពរចាប់ខុបជាប់មិនព្រមលែង ។

- ខ្ញុំមិនព្រមឲ្យបងទៅណាទៀតទេ ! បើបងចង់ដោះដៃចោលខ្ញុំ...បងយកកាំបិតមកចាក់សម្លាប់ខ្ញុំឲ្យហើយទៅ !

- ខ្ញុំប្រាប់ថាឲ្យលែងណា៎ (ទិរភ្ស្រែកគំរាម) បើនាងមិនព្រមស្តាប់ខ្ញុំ ជួនកាលអារម្មណ៍ក្តៅរបស់ខ្ញុំអាចកំរើកឡើងម្តងទៀត ...

អម្ពរមិនព្រមលែង នាងនៅតែខ្នេញពាក្យដដែលថា ៖

- ខ្ញុំមិនព្រមឲ្យបងទៅណាទៀតទេ ! បើបងចង់ដោះដៃចោលខ្ញុំ ... បងយកកាំបិតមកចាក់សម្លាប់ខ្ញុំឲ្យហើយទៅ ...

- បើប្រាកដជាមិនព្រមលែងដៃខ្ញុំ ! នាងឯងត្រូវតែទទួលទារុណកម្មពីខ្ញុំម្តងទៀត

ថាហើយ ទិរភក៏ទម្លាក់រលីសចោលទៅលើគ្នា ។

ក៏បែរមកចាប់ក្រញ៉ូមសក់អម្ពរទាញគ្រវីគ្រវាត់បីបួនជុំ រួច
ក៏យារដៃដាល់ចំមុខ ក ស្មា ទ្រូងនាងយ៉ាងកាចសាហាវ យារ
យៅគ្មានត្រាប្រណី ។ លោហិតស្រស់ ៗ ហូរចេញពី
ប្រមុះមាត់នារីកំសត់ជាលើកទីពីរ ។ នាងដួលដេកក្រោក
លែងរួចទៅហើយ តែសម្លេងស្រែកអង្វរករនៅតែឮ
ខ្សាវ ៗ ចេញពីមាត់នាងមកទៀត ៖

– បងទិព .. បងកុំទៅណាចោលខ្ញុំ .. បងសម្លាប់
ខ្ញុំឲ្យហើយទៅ ... សម្លាប់ខ្ញុំភ្លាមទៅបងទិព ... ខ្ញុំបន់ស្លាប់
ដោយស្នាដៃប្ដីសម្លាញ់ណាស់ !

បានជួបចិត្ត! មនុស្សក្នុងវិញ្ញាណរបស់សត្វតិរច្ឆាន
ស្ទុះទៅក្រញ៉ូមសក់ដ៏វែងអន្ទាយរបស់អម្ពរ អូសទាញទៅរក
បន្ទប់ទឹក ។ គេដាក់ខ្លួននាងទប់ជើងមិនអស់ ត្រាតែនាង
រមៀលចូលទៅក្នុងបន្ទប់ គេក៏ទាញទ្វារបិទដាក់គន្លឹះ ។

– ស្លាប់ទៅចុះមីចង្រៃ

ទឹកស្រែកគំរាមជាលើកចុងក្រោយ  រួចគេក៏ដើរមក
រើសវ៉ាលីស ដើរចេញពីផ្ទះកំសត់ ៗ  ហៅស៊ីក្លូឡើងជិះ
តម្រង់ទៅផ្ទះនាងសោភាមេម៉ាយស្រីកំណាន់ចិត្ត ៗ

. . . . . . . . . . . .

ហេមន្តរដូវរំលងផុតទៅ  គិម្ហរដូវក៏ផ្លាស់វេនចូលមក
ជំនួសវិញ ៗ

អម្ពរនារីកំសត់  ក្រោយពីទឹករ៉ាយនាងធាក់បញ្ចូល
បន្ទប់ទឹក  បន្តិចមកក៏មានគេអ្នកជិតខាងផ្ទះមកជួយបើកទ្វារ
បន្ទប់ទឹកឱ្យនាង  ហើយនាំនាងទៅព្យាបាលគ្រាតែរេះមុខ
របួស  ជាសុខភាពដូចប្រក្រតី

កាលបើអស់សង្ឃឹមថាប្ដីលែងវិលមកវិញហើយអម្ពរក៏នឹក
ភ័យខ្លាចមិនហ៊ានទៅផ្ទះមួយស្ងាត់ម្នាក់ឯង ៗ នាងបានសុំស្នូល
ផ្ទះនៅចូលជាមួយមីងរៀមអ្នកជិតខាង  ដែលធ្លាប់ជួយនាង
ក្រោលថ្ងៃទឹករ៉ាយបញ្ចូលបន្ទប់ទឹក ៗ

ទុក្ខត្រូវតែលើទុក្ខទ្វេឡើងជារៀងរាល់ថ្ងៃ ឥឡូវនាងនឹក
រឭកស្រុកនឹកឪពុកម្តាយ នឹកកាលខ្លួននៅពីក្រមុំ ធ្លាប់ស្រណុក
កាយសប្បាយចិត្ត ៗ មានឈ្នួលប្រុសស្រីសំរាប់ហៅប្រើ
ឯប្រាក់កាសទៀតសោត ក៏សម្បូណ៌ហូរហៀរមិនចេះខ្វះ
ខាត ៗ ឥឡូវចេះព្រួយសព្វគ្រប់ រឿងរស់នៅស្រុកគេ
ម្នាក់ឯង ៗ ព្រួយរឿងប្រាក់កាសសម្រាប់ចិញ្ចឹមជីវិតនិង
ឈ្នួលផ្ទះ ៗ ព្រួយមិនដឹងអនាគតខាងមុខ ជីវិតនាងនឹង
ប្រែប្រួលយ៉ាងម៉េចទៅទៀត ៗ នាងចង់ត្រឡប់ទៅស្រុក
កំណើតសុំខមាទោសពីឪពុកម្តាយ តែចិត្តមួយធ្វើឲ្យនាង
គិតឃើញថា នាងបានបំផ្លាញកិត្តិយសឪពុកម្តាយ ឈ្មោះ
នាងស្អុយដូចគំរង់ពេញទាំងស្រុក ៗ បើនាងវិលទៅវិញ
ក៏ទុកដូចជានាំក្លិនអសោចចូលស្រុកម្តងទៀត ៗ ម្ល៉ោះហើយ
បើបានជាខកខុសដើរចេញពីស្រុកមកប៉ុណ្ណោះ ត្រូវតែទ្រាំ
រស់នៅសងបំណុលកម្មទៅចុះ ធ្វើម្តេចជាតិនេះជាជាតិ

អក័ពូ ។

មីងរឿមស្ត្រីចិត្តធម៌ឃើញអម្ពរខំដើរលក់ឆ្នោតជាតិម៉្យៗរាល់ល្ងាច បានកំរៃតិចតួចស្ដួចស្ដើងមិនគ្រប់គ្រាន់នឹងការចាយវាយ ។ មើលទៅដូចជាវេទនាក្រៃពេក គាត់ក៏ទៅសុំការក្នុងហាងទំនិញរបស់ក្មួយគាត់ឲ្យនាងធ្វើ គឺធ្វើជាអ្នកចាំទទួលប្រាក់ ( caissière )

អម្ពរ តាំងពីបានចូលទៅធ្វើការក្នុងហាងទំនិញ« មេ-ត្រីពាណិជ្ជ » របស់លោកពង្ស សំអឿនក្មួយមីងរឿម ៗ នាងក៏ធ្លងផុតពីឋានៈទុព្វលភាពមកជាមធ្យមភាព ។ គ្រប់គ្រាន់ចាយវាយចិញ្ចឹមជីវិត លែងខ្វះខាតអត្តខាត់ដូចជាពេលមុនទៀត ។

លោកពង្ស.សំអឿនជាកម្លោះចាស់ ៗ លោកបណ្ដោយវ័យលោកឲ្យវិលមកដល់អាយុហាសិបឆ្នាំ ដោយមិនព្រមរៀបរស់នៅនឹងស្រីញីណាឡើយ ។ ទាំងនេះមិនមែន

ថាលោកស្អប់ខ្ពើមស្ត្រីទេ លោកបេះនឹកព្រឺព្រួចបេះស្រឡាញ់ស្រីដូចគេម្នាះខ្លួនទៅដែរ តែចំពោះនារីដែលលោកត្រូវការរើសមកធ្វើជាមេផ្ទះបង្គោលគ្រួសារ លោកនៅមិនទាន់ឃើញពេញចិត្តណាមួយសោះ ។

ជាបែជន្យ ជាគួរព្រឹងប្អូកម្មគួគាប់អ៊ូក៏មិនដឹងដែរ នៅពេលបានអម្ពរមកធ្វើការជាមួយ លោកសំអឿនក៏បេះពេញចិត្ត ហើយយូរៗមកក៏ប្រែក្លាយទៅជាស្រឡាញ់យកតែម៉ែនទែន តាំងខ្លួនលោកដឹងដែរថា អម្ពរជាស្រីមេម៉ាយៗ

ចំពោះអម្ពរនាងមិនបានដឹងថាលោកចាំងហ្វាង „មេត្រីពាណិជ្ជ" លួចស្រឡាញ់នាងក្នុងផ្លូវស្នេហាទេ នាងយល់ថាលោកសំអឿនស្រឡាញ់ពេញអាននាង ក្នុងឋានៈចៅហ្វាយស្រឡាញ់បាវបំរើប្តូបងស្រឡាញ់ប្អូនប៉ុណ្ណោះ ។

រីឯចិត្តនាងវិញ គឺគ្មាននឹកគិតលួចស្រឡាញ់លោកសំអឿនសូម្បីតែតិចតួច ព្រោះនាងខ្លាចហើយក្រែងហើយ!

ខ្ពួតហើយ ទំនងមនុស្សគ្រប់រូបដែលមានភេទជាប្រុស ៗ ដំបៅចាស់របស់នាងនៅស្នាមក្រៅឡើយមិនទាន់រលប់ ៗ ប្អូនកាលធ្វើឲ្យនាងនឹកឃើញរឿងដើម តើតបុក.ចាប់ក្នុងខ្លួនឡើងវិញម្តងៗដែរ ៗ

នៅពេលណាទំនេរពីកិច្ចការជំនួញ លោកសំអឿនតែងមកអង្គុយនិយាយដដែកលេងជាមួយនាង, រាប់រឿងពីនេះពីនោះហើយក៏សួរមកដល់រឿងជីវិតនាងថា ៖

– ប្តីនាងគេឈប់មករកនាងមែនទែនហើយឬ ?

– ចាស ! គេឈប់មករកខ្ញុំហើយ គេធ្វើឲ្យខ្ញុំទទួលសេចក្តីឈឺចាប់ក្នុងជីវិត យ៉ាងសែនខ្លោចផ្សាជាទីបំផុត ...

– ចុះឧបមាថា មានអ្នកណាម្នាក់គេចូលមកស្តីដណ្តឹងនាងរៀបការ តើនាងយល់ព្រមទេ ?

– ចារឿងមនុស្សប្រុសមួយ ខ្ញុំរាងហើយលោក បើសិនជានាងខ្ញុំគាបគមមាត់មិននិយាយស្តីដូចព្រះនាងសុវណ្ណ

កេសរក្នុងរឿងសព្វសិទ្ធបាននាងខ្ញុំតាំងចិត្តថានឹងមិននិយាយស្ដីរកប្រុសរហូតទល់ថ្ងៃស្លាប់ ...

– នាងនិយាយហ្នឹង ដូចជាទម្លាក់កំហុសទៅលើភេទប្រុសខ្លាំងពេក ក្នុងលោកយើងនេះមិនមែនមានប្រុសអាក្រក់ដូចជាប្ដីនាងទាំងអស់គ្នាឯណា ? ប្រុសដែលគេល្អចិត្តស្មោះត្រង់នឹងប្រពន្ធក៏មានច្រើនដែរ ! ..

– បាស ! នោះចំពោះនារីដទៃ ចំពោះខ្លួននាងខ្ញុំ ពុំដែលបានទទួលការថ្នាក់ថ្នមពីប្ដីដូចលោកមាន ប្រសាសន៍ទេ

– ឯចឹងបានសេចក្ដីថា នាងសុខចិត្តនៅព្រោមមិនព្រមយកប្ដីរហូតដល់ចាស់ស្លាប់ឬ ?

– បាស ! បើសិនជានាងខ្ញុំគេចវៀសពុំបាន នាងខ្ញុំតាំងចិត្តថានឹងព្យាយាមចៀសឲ្យរួចរហូត !...

លោកសំភឿន កាលបើអម្ពរនិយាយតឹងរឹងដូច្នេះ

លោកក៏លែងហ៊ានដេញដោល ហើយក្រោកដើរចេញ ឆ្ងាយពីនាងទៅ ។



ម៉ៅ–កុសុមោ
Kusumo MAO

## ៥

### មិនស្នេហ៍ តែអាណិត

ជាតិនេះឈប់ជឿ ជឿពាក្យប្រុស
ជីវិតខកខុស ខុសខ្លោចផ្សា
ស្រីឆ្លើយមិនស្នេហ៍ មិនស្នេហា
តែចិត្តប្រាប់ថា ថាអាណិត ។

– មនុស្សគ្រប់រូប, គ្រប់វណ្ណៈ គ្រប់សាសន៍ជាតិ ពណ៌សម្បុរ សុទ្ធសឹងធម្មជាតិបង្កើតឡើងមកទាំងអស់ ហើយមនុស្សទាំងនេះមិនអាចប្រព្រឹត្តអ្វី ឲ្យហួសពីក្រិត្យក្រម របស់ធម្មជាតិបានដែរ ។

ធម្មជាតិបង្កើតពិភពលោក បង្កើតមនុស្សសត្វព្រឹក្សា លតាវល្លិ៍ បង្កើតទឹកដីព្រះអាទិត្យ ព្រះចន្ទ ផ្កាយ ខ្យល់ ភ្លៀង ។ ធំបំផុត គឺបង្កើតសេចក្តីស្នេហា ទោះជាតាក្យុ ស្នេហានោះស្ថិតនៅក្នុងវ័យណាក៏ដោយ ។

បើគ្មានស្នេហា ពិភពលោកទាំងមូលត្រូវរលាយ ពពួកសត្វលោកត្រូវផុតពូជ ហើយមនុស្សនឹងបាញ់ ចាក់ កាប់សម្លាប់ បង្ហូរឈាមគ្នាគ្មានពេលឈប់ ។

ដូច្នេះ លោកសំអឿននិងនាងអម្ពរជាមនុស្សលោក ដែលធម្មជាតិបានបង្កើតឡើងមកដែរ តើអាចគេចរួចពី សេចក្តីស្នេហាបានឬទេ ? ដើម្បីឆ្លើយតបនឹងសំនួរនេះអ្នក

និពន្ធ សូមអញ្ជើញអស់លោកអ្នកអាន ធ្វើដំណើរដោយក្រសែចក្ខុ តាមមើលដំណើរជីវិតរបស់អ្នកទាំងពីរតទៅទៀត ។

លោកពន្ធ - សំអឿន ព្យាយាមរក្សាខ្លួនឲ្យស្និទ្ធនិងអម្ពរជាទីបំផុត ហើយមិនយូរប៉ុន្មានអ្នកទាំងពីរក៏ចុះចិត្តស្និទ្ធស្នាលគ្នា រហូតហ៊ានជិះរថយន្តទៅណាមកណា តែពីរៗនាក់ ។

លោកពន្ធ-សំអឿនបបួលអម្ពរទៅលេងកែប អម្ពរងក់ក្បាលទទួលពាក្យភ្លាមដោយមិនបាច់គិត ។

ទៅដល់កែប លោកសំអឿននាំអម្ពរទៅដើរលេងតាមកន្លែងសប្បាយនានាដូចជាសួនសត្វ ផ្សារក្រុងកែប កន្លែងតាំងពិពណ៌ ជិះទូកក្តោងធ្លងទៅលេងកោះទន្សាយ ។ល។ ផុតពីហ្នឹង ពេលរសៀលត្រជាក់ គេនាំគ្នាងូតទឹកសមុទ្រឬដើររើសសំបកខ្យងខ្ចៅតាមឆ្នេរខ្សាច់ ។

នៅលើផ្ទៃមុខម្នាក់ៗ សុទ្ធសឹងពោរពេញទៅដោយអាការសប្បាយរីករាយ សើចញញឹមប្រិមប្រិយ៍ ។ បញ្ជាក់ឲ្យដឹងថា គេគ្មានកង្វល់ព្រួយពីរឿងអ្វីបន្តិចបន្តួចឡើយ ។

មែន អម្ពរសប្បាយរីករាយ ព្រោះជាលើកដំបូងបំផុតក្នុងជីវិតរបស់នាង ដែលបានមកស្គាល់សមុទ្រកែប ។ រីឯលោកសំអឿនវិញលោក ក៏សប្បាយរីករាយជាលើកដំបូងបំផុត ក្នុងជីវិតរបស់លោកដែរ ព្រោះលោកសម្លឹងរកអនាគត នារីមុទ្ទូររបស់លោកឃើញ ហើយបាននៅជិតនារីនោះតទល់តែពីរនាក់ទៀត ។

ល្ងាចនេះ ក្រោយពីស្រស់ស្រូបអាហារល្ងាចរួចរាល់ លោកសំអឿនក៏នាំអម្ពរទៅអង្គុយយកខ្យល់សមុទ្រ ពេលព្រះអាទិត្យហៀបអស្តង្គត ។

ព្រួញកាមទេព បាញ់ទំលុះបេះដូងលោកចាងហ្វាង „មេត្រីពាណិជ្ជ" ឲ្យរន្ធត់ញាប់ញ័រសព្វសារពាង្គកាយ ។

ភ្លើងស្នេហ៍ឆាបឆេះក្នុងទ្រូងពេញបន្ទុកៗ អត់ទ្រាំតទៅទៀតលែងបាន កម្លោះចាស់ ក៏ប្រថុយនិយាយទាំងញ័រញើតញាក់ញើមទៅកាន់ caissière ខ្លួនថា ៖

– ណា! នាង! ខ្ញុំបង់ដំរាបការម៉្យាងណា ... នាងអនុញ្ញាតឲ្យខ្ញុំនិយាយទេ ?

អម្ពរកំពុងដក់ក្អែកទេសភាព មាត់សមុទ្រពេលថ្ងៃលិច លុះឮលោកសំអឿនបន្លឺពាក្យទន់ប្លែកដូច្នេះ នាងក៏បែរមកមើលមុខលោកដោយទឹកឆ្ងល់៖

– រឿងអ្វីទៅលោក ? សូមលោកមានប្រសាសន៍មកចុះ! ..

– លាក់បាំងអ្វីនាង ... ខ្ញុំសព្វថ្ងៃស្រឡាញ់នាង គឺជាសេចក្ដីស្រឡាញ់ដល់ដុះចេញពីប្រអប់បេះដូង បរិសុទ្ធតែ ... បើសិនជាពាក្យសារភាពនេះធ្វើឲ្យនាងមិនសប្បាយចិត្តណា... សូមនាងអភ័យទោសដល់ខ្ញុំផង ...

- លោកស្រឡាញ់ខ្ញុំ ?

ស្ត្រីមេម៉ាយឱពាន

- ពិតហើយនាង ខ្ញុំស្រឡាញ់នាង...

លោកសំអឿនឆ្លើយ រួចក៏ឱនមុខជ្រប់ ៗ

អម្ពរ នាងមិនស្អប់លោកសំអឿនទេ នាងស្រឡាញ់លោក ស្រឡាញ់របៀបកូនឈ្នួលស្រឡាញ់ចៅហ្វាយ ឬអូនស្រឡាញ់បង ៗ នាងមិនដែលគិតស្រឡាញ់ទៅលើផ្លូវស្នេហាកាមកិលេសឡើយ ។ ដល់នៅស្ងៀម ៗ ស្រាប់តែបោទស្នួរដូច្នេះ នាងក៏មានចិត្តកវែកគឺស្រឡាញ់ មិនស្រឡាញ់ស្ថិតនៅជាអាថ្រាកណ្ដាល ។

-នាងប្រហែលខឹងខ្ញុំហើយ បានជានៅស្ងៀមមិនឆ្លើយតប !...

លោកសំអឿនមានប្រសាសន៍ម្ដងទៀតកាលបើឃើញអម្ពរស្ងាត់ស្ងៀមយូរ ។

គម្ពរបែរទៅ ទៅញញឹមស្ងួតល្ងង់ចិត្តលោកសំគឿនបន្តិច ទើបនាងបន្ទឺរវាតិចៗថា ៖

– ខ្ញុំមិនខឹងលោកទេ ហើយមិនដែលនឹកតាំងចិត្ត ខឹងម្ដងណាផង !...

– បើតបឹងបានសេចក្ដីថា នាងព្រមស្រឡាញ់ខ្ញុំហើយ មែនទេ ?

លោកសំគឿន ឲ្យសេចក្ដីយល់ឃើញខ្លួនឯង លេប តែរក្លួតជារស្ពឺ ៗ

គម្ពរ នាងនឹកអាណិតទៅហ្មាយកម្លោះពន់ពេកក្រៃ តែ នាងក៏មិនហ៊ានអាសគាត់ សំរេចចិត្តខ្លួនឯងយ៉ាងណា ក្រៅ ពីឆ្លើយទៅមាណពវិញថា ៖

– កុំទាន់ឲ្យខ្ញុំឆ្លើយក្នុងពេលនេះធ្វើអ៊ីលោក!... សូមឲ្យ លោកពប់អានខ្ញុំក្នុងឋានៈជាប្អូនសិនចុះ ព្រោះនៅមានពេល វេលាច្រើនណាស់ ដែលខ្ញុំនឹងដកដាលោកឲ្យបានជ្រាប .!

បានស្ដាប់ពាក្យផ្អែមស្រទន់ ប្រកបដោយកិរិយាសុភាព រាបសាររបស់ស្រស់ស្រី បើទុកជាមិនទាន់ឲ្យសេចក្ដីសង្ឃឹមប៉ុន្មាន ។ នេះក៏មានសេចក្ដីសុខជួរជ្រួង នឹកសប្បាយចិត្តយ៉ាងចម្លែក ។

ព្រឹកស្អែកឡើង កម្លោះមេម៉ាយពីរស្ដារក៏នាំគ្នាធ្វើដំណើរមកកាន់វត្តនាទីវិញ ។

. . . . . . . .

មួយខែក្រោយមក...

លោកពង្ស-សំអឿនរង់ចាំទទួលចម្លើយស្នេហាពីមាត់អម្ពរ ដូចសំណាបដកការង់ចាំទទួលទឹកភ្លៀងដើមឆ្នាំ ។

ចាំបាត់!.. ចាំបាត់មិនព្រមឆ្លើយតប កម្លោះចាស់ក៏ប្រមូលស្មារតីលើកអម្ពរម្ដងទៀត នៅពេលដែលគេនាំនាងទៅលេងខេត្តបាទី ៖

– អត់ទោសនាង!... រឿងភ្ជឹងនាងសំរេចយ៉ាងម៉េច

ទៅហើយ ?

- រឿងអ្វីលោក ? អ៊ូ ! នឹកឃើញហើយរឿងលោកប្រាប់ខ្ញុំពីថ្ងៃសៅរ៍មុនថាចង់ទៅញុំាបាយផ្ទះខ្ញុំម្តងនោះឬ ? មិនអីទេ ? លោកចង់អញ្ជើញទៅថ្ងៃណាក៏បានដែរ ...

អម្ពរធ្វើជាពើនិយាយចាកប្រធាន បែកផ្លូវទៅឯណាឯណោះវិញ ។

- មិនមែនរឿងហ្នឹងទេនាង ! (លោកសំអឿននិយាយម្តងទៀត) រឿងអា... ដែលខ្ញុំសុំឲ្យនាងឆ្លើយកាលនៅមាត់សមុទ្រកែបនុ៎ះអី ?

ម្តងនេះ អម្ពរនាងងក់ក្បាលទទួលដឹង ។

- កុំទាន់អាលខ្ញុំឆ្លើយអីឬលោក ?

- អាណិតឆ្លើយ ពេលឥឡូវទៅនាង... បើមិនដូច្នេះទេ ខ្ញុំប្រេះទ្រូងស្លាប់ហើយ ...

លោកសំអឿន និយាយធ្វើមុខសោកគួរឲ្យអាណិត ។

– ខ្ញុំមិនស្អប់ខ្ពើមលោកទេ ... ( ស្រស់ស្រីនិយាយ) ផ្ទុយទៅវិញខ្ញុំនឹកត្រេកអរណាស់ដែលមនុស្សយ៉ាងខ្ញុំ មានកិត្តិយសបានលោកស្រឡាញ់ ខ្ញុំក្រីក្រហើយមេម៉ាយ លោកក៏ជ្រាបស្រាប់...ហានះ ខ្ញុំមិនសាកសមធ្វើជាភរិយារួមជីវិតរបស់លោកឡើយ សូមលោកបំភ្លេចរូបខ្ញុំចោលហើយ ស្តីដណ្តឹងកូនក្រមុំធនបតី ដែលមានវណ្ណៈស្មើនិងលោក រៀបការចុះ ... បំភ្លេចស្រីអនាថានេះចោលទៅលោក ..

– មាសប្រាក់ហានះ មានឬអ្នកក្រមិនមែនជាបញ្ហាសំខាន់សំរាប់ខ្ញុំទេ ... ហើយក្រមុំឬមេម៉ាយក៏មិនមែនជាឧបសគ្គក្នុងដំណើរជីវិតស្នេហាដែរ...

ដែកថែបរឹងយ៉ាងណា ត្រូវភ្លើងយូរទៅគង់រលាយ រីឯទឹកចិត្តអម្ពរដែលកាន់ទិដ្ឋិមានះ យកប្រុសគេធ្វើជាគូសត្រូវប្រហារជីវិត ។ ត្រូវប្រុសប្រាណអង្វរគេច្រើនលើកច្រើនសាក៏ទន់ចិត្ត ។ នាងឆ្លើយទ្រង់នៅអៀន ៗ ទៅលាន់

ប្រុសកម្លោះថា ៖

-បើលោកពិតជាស្រឡាញ់ខ្ញុំដោយសុទ្ធចិត្តខ្ញុំសូមអង្វរលោកឲ្យករុណាតខ្ញុំប្រើតជានិការស្រឡាញ់ ... សូមលោកកុំធ្វើឲ្យខ្ញុំខកខុសក្នុងដំណើរជីវិតជាលើកទីពីរឲ្យសោះ...

លោកសំអឿន សែនពេកសោមនស្សរីករាយក្នុងចិន្តា ៗ លោកទាញប្រាណនារីមកផ្ដេកលើទ្រូងបន្ទឺពាមួយៗឡើងថា ៖

- ពេលនេះឲ្យខ្ញុំសុំហៅនាងថាអូនហើយហៅខ្ញុំថាបងវិញទៅណា...!

- បាស !...

- អូនអម្ពរ!...

- បាស...បង...!

អម្ពរនាងឆ្លើយទ្រង់អឿននៅឡើយ ។

- ពីថ្ងៃនេះទៅ រូបយើងទាំងពីរប្រហែលជាគ្មានឧប-

សត្វអ្វី     ក្លួលមកជ្រៀតជ្រែកទៀតទេ... បងនឹងដាក់បណ្ដាំ ម៉ាក់បងឲ្យលោកចូលស្ដីដណ្ដឹងអូនពីមីងរឿម   ហើយគាត់ តែងរៀបមង្គលការឲ្យរហ័សជាទីបំផុត

— បងទុកចិត្តថាឪពុកម្ដាយបងពេញចិត្តនឹងអូនដែរឬ ?

— គ្មានអ្វីគួរឲ្យសង្ស័យទេអូន.. ចិត្តបងយ៉ាងណា ចិត្តឪពុកម្ដាយបងក៏យ៉ាងដូច្នោះដែរ យើងពាស់ស្វាប់រៀងៗខ្លួនៈ

អម្ពរ  សែនពេញចិត្តនឹងពាក្យធានាប្រកបដោយមធុរភាពរបស់លោកសំអឿន ។  នាងអន្លួយស្រមើលស្រម័យឃើញភាពសុខមង្គលក្នុងពេលអនាគត ។  នាងទុកចិត្តទៅលើគុណសម្បត្តិគេដោយឥតសង្ស័យ ។

លោកសំអឿននិងទិពប្ដីនាងមុន   នាងយកមកប្រៀបផ្ទឹមគ្នាឃើញថាខុសឆ្ងាយមេឃនឹងដី ។   លោកសំអឿនមិនចេះនិយាយច្រើន   មិនចេះពោលពាក្យ ផ្អែមល្ហែមតាមក្នុងសៀវភៅរឿងប្រលោមលោកហើយជាពិសេស   ដែល

ម៉ៅ-គុសុមោ
Kusumo MAO



នាងពេញចិត្តជាងគេ គឺសំអៀនមិនបេះប្រើពាក្យស្បថមួយពាន់ពាក្យជួចទិវា ។

លក្ខណៈខាងលើទាំងប៉ុន្មាននេះហើយធ្វើឲ្យនាងកាន់តែពេញចិត្តលើប្រុសគម្លោះខ្លាំងឡើងៗជាលំដាប់ ។ នាងមិនស្រឡាញ់គេទេតែនាងអាណិតគេ អាណិតរកអ្នកក្នុងលោកមកប្រដូចមិនបាន គឺមិនស្នេហ៍តែអាណិត ។



## ៦

### បុរសភ្ញាក់ខ្លួន

ពេលដឹងខ្លួនខុស ខុសហួសអស់
ប្រពន្ធក្រោយស្រស់ ស្រស់ពេស៊ីរ្យា
រោងពុម្ពឲ្យឈប់ ឈប់ធ្វើការ
សង្ស័យរាសនា វាសនាដាក់ៗ

អស់លោកអ្នកអាន ប្រហែលជានៅមិនទាន់ភ្លេចទឹកនេះមើលទៅ? ឥឡូវអ្នកនិពន្ធសូមនាំក្រសែចក្ខុលោកអ្នកអានទៅមើលជីវភាពរស់នៅរបស់នាយប្រុសអប្រិយ៍នេះម្ដង ។

ទិវ៉ា កាលដ្បានតាំងមកនៅជាមួយនាងសោភាដំបូងសប្បាយរីករាយ, សុខស្រួលរមូលក្រពើ, ជាមួយគ្នាល្អួនល្អឹនសំបើមដៃណាស់ ៗ សោភាស្រីមាយាខំយកចិត្តទុកដាក់បំរើផ្គាប់ផ្គុណទិវ៉ាមិនឲ្យទាស់អារម្មណ៍ ។

រសនាមនុស្សគេថាមិនបានស្អាតមិនត្រូវ ។ កំពុងតែសុខស្រួលនឹងគ្នា ស្រាប់តែថ្ងៃមួយម្ចាស់រោងពុម្ពក៏បញ្ឈប់ទិវ៉ាលែងឲ្យធ្វើការ ដោយហេតុទម្លាក់ទោសកំហុសទៅលើគេថាជាមនុស្សធ្វេសប្រហែសនឹងការងារ ។

សោភាគ្រាន់តែលេចឮដំណឹងនេះនាងក៏ប្រែឥរិយាបទលែងស្លូវរីវល់នឹងទិវ៉ាដូចពេលមុនទៀត ព្រោះនាងដឹងថាអស់សាប់ការទៀតហើយ ។

កន្លងពីរបីខែក្រោយមក ចចកនៅតែរត់រកស៊ីការធ្វើមិន បាន១ៗ សោភាក៏បែកចិត្តទៅមានសហាយថ្មីហើយព្យាយាមរក រឿងរកហេតុ ឈ្លោះប្រកែកនិងចចកស្ទើរតែគ្មានលោះថ្ងៃណា ដូចថ្ងៃនេះជាដើម សោភាត្រឡប់មកពីដើរលេងជាមួយប្រុស សហាយថ្មី នាងក្រឡេកឃើញចចកដេកគងថ្ងាសកើតទុក្ខ ៗ នាងក៏តាំងពាក់មុខយក្សដើរទាត់បានទាត់ខ្លាំង ស្រែកដេរ គាឡូគាឡា ទៅកូនខ្ពតៀរោមស្រមូវ ឈ្មោះតាលុចជាទំនង ដាក់ផ្ដាឲ្យចចកថា ៖

— នែ៎ ! តាលុច! តាខ្ពតៀហ្អែននេះគ្មានបេះព្រួស បេះដើររកស៊ីគីខ្លួនឯងខ្លះផងទេ ! តាងតែមានគេចាំរត ឲ្យស៊ីស្រាប់ក៏គិតតែពីស៊ីរួចដេក ទើបតែពីដេកស៊ីទៀត ឃើញជោគអីក៏ជោគលើសខ្ពតែឯងម៉្លេះញ៉ែ ! បើនៅតែខ្ជិល របៀបនេះតទៅខែទៀត ច្បាស់ជាអញប្រកការុងយកហ្អែង ទៅបំបរបង់ហើយ !

សុនខគឿ ឈ្មោះអាលុច ហេតុតែវាមិនចេះស្តាប់ភាសាមនុស្ស ឃើញសោភាដេរដេញឈ្មោះវា វាក៏ស្ទុះចូលមកបក់កន្ទុយរវិច ៗ លិទ្ធជើងលិទ្ធដៃចៅហ្វាយស្រីថ្លែងសេចក្តីស្វាមីភក្តិ ជាហេតុហុចឱកាសល្អឲ្យសោភាបន្ថែមផ្លែផ្កាកាន់តែស្រួលជាងមុនទៅទៀត ៖

– នែ! កុំមកលិទ្ធជើងលិទ្ធដៃអញ! ថយចេញពីអញឲ្យឆ្ងាយទៅ អញស្អប់មុខអាឆ្កែឯងណាស់! ឆ្កើយដេកកន្លែងណាកន្លែងហ្នឹងឡើងស្អុយជួចគំរង់

សោភាដេរឆ្កែ តែក្អួតទាន់ល្មមវែកចុងទៅមើលទិវាម្តង ៗ

ពាក្យដេរឆ្កែចាំងអម្បាលម៉ាន រត់ចូលទៅក្នុងត្រចៀកទិវាស្មើរបែកក្រដាស់ ៗ នាយកំហូចយើងយល់ណាស់ទៅ ហើយថាសោភាដេរអាលុចនេះ គឺដេរឲ្យខ្លួនគេតែម្តង ៗ

ទិវាខំប្រឹងខាំមាត់អត់ធ្មត់សង្កត់ចិត្ត ធ្វើជាដេកមិនឮ តែសោភានៅជេររអ៊ូរៗក្បែររន្ធត្រចៀកមិនព្រមឈប់ ។

ហួសវិស័យនឹងរម្ងាប់ទោសៈបាន ទិវាក៏ស្ទុះក្រោកពីលើគ្រែដើរទៅសួរសោភាថា ៖

- អូនឯងជេរអ្នកណាហ្នឹង ?

- ខ្ញុំជេរឆ្កែ !

សោភាឆ្លើយកំបុត ។

- ហ៊ឺះ ! មិនបាច់ដៀមដាមដាក់ថ្លៃដាក់ផ្កាឲ្យបងច្រើនទេអូនអើយ ! មនុស្សដូចបងឆាប់យល់ណាស់ !

- យល់យ៉ាងម៉េច ! ( សោភាទឹមបង្កើះបែរមុខមកសង្ស្យក ) ខ្ញុំជេរឆ្កែបងឯងក្ដៅក្រហាយដែរ ? បងឯងក្រែងមនុស្សឬឆ្កែ ?

ដល់ត្រូវសោភាលេងជេរដាក់ចំមុខដូច្នេះ ទិវាក៏ឡើងក្រហមស្លឹកត្រចៀកដូចស្លឹកត្រចៀកមាន់គគមួយរំពេច ។

- អូនឯងឥឡូវរាងឡើងដៃខ្លាំងហើយ ( ទិរានិយាយ ) កាលបងនៅមានការធ្វើ នៅមានប្រាក់ឲ្យយកទៅស៊ីចាយ បាយផ្ការ អូនល្អនឹងបងណាស់ ! លុះបងអស់ការធ្វើ ក្រប្រាក់ ! អូនក៏បែកចិត្តភ្លេចគ្រាដើមអស់រលីង ! ចិត្តអូនអ៊ីក៏ឆាប់ប្រែប្រួលភ្លាម ៗ មើលតែចុងស្រល់ត្រូវខ្យល់បក់ម្ល៉េះ ?

- ហ្អឹងហើយចិត្តខ្ញុំរាងចឹង ! ( សោភានិយាយតបព្រាយ ឆ្លើយមកវិញ ) បើបងថាខ្ញុំជាមនុស្សស្រឡាញ់ប្រាក់ដែរម្ដេចក៏មិនទំរកប្រាក់មកឲ្យខ្ញុំចាយ ? ខ្ញុំឥឡូវអត់អង្ករទេ ! ទ្រាំនៅបានក៏បាន បើទ្រាំនៅមិនបានទេអញ្ជើញចេញទៅចុះ ទុះ ! មាត់ទ្វារ !

សោភានិយាយព្រមទាំងចង្អុលដៃប្រាប់ទិរា ៗ

បុរសក្ដួតស្នេហ៍ ក្ដៅមុខក្ដៅមាត់ដូចមាន់ប្រជល់ ៗ គេចងតែស្ពុះទៅការកហុតឈាម ឲ្យសមនឹងកិរិយា

ព្រហើនប្រឡោងតាមរបស់សោភា តែចិត្តគេមិនហ៊ាន ព្រោះគេនៅស្រឡាញ់នាងនៅឡើយ ។ ម្ល៉ោះហើយដើម្បីឲ្យស្ងប់ស្ងាត់ ទិវាក៏ទ្រាំធ្វើគធ្វើថ្លង់ទៅអង្គុយខាងក្រោយផ្ទះ បណ្តោយឲ្យសោភានាងកក់ទឹកមាត់ ជេរទាល់តែហត់បាត់សម្លេងខ្លួនឯងទៅ ។

ថ្ងៃមួយ ទិវាត្រឡប់មកពីដើររកការធ្វើមិនបាន ឈានជើងឡើងដល់លើផ្ទះ ឃើញបិទទ្វារមុខជាប់ កើតក្តីសង្ស័យ ព្រោះមិនដែលមនុស្សនៅបិទទ្វារទាំងថ្ងៃដូច្នេះ គេក៏ដើរចុះកែងជើងស្រាលៗ ទៅលបមើលតាមរន្ធសោរ ស្រាប់តែឃើញសោភាប្រពន្ធសម្លាញ់គេ ស្រាតខ្លួនទទេដេកឱបថើបថ្នែនជាមួយមនុស្សប្រុសម្នាក់ ដែលគេពុំធ្លាប់ស្គាល់ ឬឃើញមុខមកពីមុនឡើយ ។

ក្មេងស្នេហ៍ ក្មេងប្រចណ្ឌឆេះពេញទ្រូងទិវាមួយរំពេច ។ បុរសវក់ឈាម ធាក់ទ្វារផ្ទះខ្ទាំង ៗ បីបួនជើងទាល់តែបាក់សោរ

រហែកឃ្លាំងចេញមក ។

ទិវាស្ទុះទៅរកអ្នកទាំងពីរ ដែលកំពុងស្រវាសំលៀកបំពាក់រៀងៗ ខ្លួនយកមកស្លៀកបិទបាំងកេរ្តិ៍ខ្មាស់ ។ បំរុងវាយឲ្យស្លាប់ទាំងពីរអ្នកនៅហ្នឹងកន្លែង ។ ម្តងនេះគេមិនព្រមទទួលពាក្យអង្វរពីសេរកា ប្តីគាប្រុសសហាយជាដាច់ខាត ។ តែកាលបើចូលទៅដល់ផិតទិវា ក៏ស្រាប់តែស្ទុះរត់មកក្រោយពីរបីជំហានវិញ ព្រោះគាប្រុសសហាយនោះវាមានខ្លាចគេស្ទួចគេស្អានទុកឯណា ? គ្រឡប់ជាដកកាំបិតស្នៀតប្រវែងពីរតឹកមុខសផ្ទាវ ឃើញគួរឲ្យស្រៀវដល់ពោះវៀនខ្លី ។ លើកប្រុងស្នៀតបំពាក់ ហើយថែមទាំងបក់ដៃហៅគេឲ្យចូលទៅទៀត ។

- ចូលមកអានាង! ថយក្រោយទៅធ្វើអីវិញ!

ទិវាទឹកក្តៅក្រហាយ និងតាពោរគ្រាននារីសាហាវនេះក្រៃលែង វាល្មួចសហាយជាមួយប្រពន្ធឯងហើយ វាហៅ

ឯងឲ្យចូលទៅឲ្យវាចាក់លេងទៀត   នាយយើងនឹកតែក្នុងចិត្ត ។

- មេច ! នៅឈរគិតដល់ណា ! ចូលមកប្រឡូកគ្នាមួនមើល !

អាប្រុសសហាយនោះ  ស្រែកគំរៀនអំណាចដាក់ឲ្យវិភជាលើកទីពីរ ។

វិភ  តាមចិត្តក្លោចង់ចូលប្រឡូកម្តងៗដែរ   តែនៅនឹកខ្លាចស្លាប់   ម្ល៉ោះហើយបានស្រែកត្រឹមសម្លេងឲ្យចូលទៅប្រយុទ្ធជាមួយអាសហាយនោះថា ៖

- អាចោរម្សៀត !   ថ្ងៃនេះអញត្រូវមួសក្បាលឯងបញ្ចាលទុកឲ្យទាល់តែបាន ! ឯងលួចសហាយជាមួយប្រពន្ធអញហើយថែមទាំងចង់ចាក់សម្លាប់អញទៀត !

បុរសសហាយនោះ   ហាក់ដូចជាគ្មានឃើញតត់ស្លុតអីបន្តិចបន្តួចសោះ  ត្រឡប់ជានិយាយសើចចំអកមកគេវិញ

ថា ៖

- អ៊ូ ! សោភាហ្នឹងប្រពន្ធឯង ? ឯងបង់អ៊ូសក្បាល

អញជាក់គុកឬ ? ហា ! ហា ! ហា !... អញទទេតែដែល

ត្រូវអ៊ូសក្បាលឯងបញ្ចូលគុក ព្រោះឯងលួចបន្លំចិត្តឲ្យ

ប្រពន្ធអញព្រមស្រឡាញ់ នៅពេលដែលអញត្រូវទៅរកស៊ី

ឯប្រទេសឆ្ងាយ !

- ក្អា ! វាហ្នឹងប្ដីអ៊ូនឯងមែនឬ ?

សោភាឆ្លើយ ៖

- ចាស ! ត្រូវហើយប្ដីខ្ញុំ ! ឥឡូវប្ដីខ្ញុំគាត់ត្រឡប់មក

ពីបរទេសវិញហើយ បងលួចមកពុះចេញពីផ្ទះខ្ញុំក្នុងពេលឥឡូវ

នេះទៅ ! ក្រែងលោគាត់ទប់ចិត្តមិនបានគាំឲ្យបងពិបាក

ខ្លួន !

និយាយរួច សោភាក៏គោងស្មាប្រុសនោះស្ទុះស្ទាល

ដូចជាប្ដីប្រពន្ធមែនទែន ។

ទំរាំឈរមើលគេចងគេរឹតទិងមុខនិងមាត់ ក្តៅចិត្តស្ទើរក្អួតឈាមស្លាប់ ។ ពេលនេះ គេយល់ហើយ ថាខ្លួនគេឲ្យសោភាបោកប្រាស់ ល្ងង់គ្រប់ជប់ ។ បើគេកុំមកទាក់ទងពាក់ព័ន្ធចំណងស្នេហ៍ជាមួយស្រីពេស្យានេះ ម្លោះសមគេមានការធ្វើមានប្រាក់កាសចាយគ្រប់គ្រាន់ ។ ហើយគេនិងអម្ពរ ក៏មិនបែកធ្លាក់គ្រួសារដូចជាសព្វថ្ងៃឥចឹងដែរ ។

ទំរាំលែងហ៊ានមាត់ក ។ គេចុះដំណើរដើរល្ងោកដីដោយគ្មានគោលដៅទៅកន្លែងណាជាពិតប្រាកដ ។

ឥឡូវនេះគេភ្ញាក់ខ្លួនហើយ សេចក្តីល្អរបស់អម្ពរប្រពន្ធកំសត់ លេចត្រដែតឡើងក្នុងមនោគតិ ។ ក្នុងលោកនេះគ្មានអ្នកណាល្អលើសពីអម្ពរប្រពន្ធរបស់គេទៀតទេ ... តែគេវិលទៅជួបមុខនាងវិញម្តេចកើត បើគេរាគាក្រក់ជួរជាតិ

លើសពីសត្វតិរច្ឆានដូច្នេះ ។ ទំពំគេភ្ញាក់កំណើតជីន
ខុសត្រូវ គ្រប់យ៉ាងកក៏រសៀលណាស់ទៅហើយ ។

Kusumo MAO

# ៧

## ហួសហើយជាតិនេះ

ស្រីសូមស្មារលា　　លាក្មានត្រើយ
ក្ដីស្នេហ៍ហួសហើយ　　ហើយជីវ៉ា
យល់ឃើញតែទុក្ខ　　ទុក្ខខ្លោចផ្សា
កើតជាតិណា　　ណាប្រាថ្នាថ្មី។

ឪពុកម្តាយលោកសំអឿន ឥតយល់ទាស់នឹងគោលបំណងរបស់លោកចង់បាននាងអម្ពរទេ លោកប្រុស លោកស្រីចូលស្តីដណ្តឹងមឹងរៀម លើកជំនួនជូនចំណី ស្តុបជានាងនៅក្រមុំឥតចឹងដៃ ។ ទាំងនេះ មកពីលោកប្រុសលោកស្រីចង់ធ្វើឲ្យពេញមុខនៃគូស្វាមីភរិយាទាំងពីរ ។

ក្រោយពីលើកជំនួនភ្ជាប់ពាក្យបានកន្ទះខែ ពិធីរៀបមង្គលការរវាងលោកតង្ស-សំអឿន និងនាងឡុក-អម្ពរ ក៏ចាប់ផ្តើមធ្វើឡើងយ៉ាងគគឹកគគឹម ។ ភ្ញៀវប្រុសស្រីមន្ត្រីរាជការ អ្នកតូច អ្នកធំ ក្រមុំ មេម៉ាយ ញាតិមិត្តជិតឆ្ងាយ បានអញ្ជើញមកជាអធិបតីភាពចងដៃខ្នពាក្យ ជូនពរសព្វសាធុការដល់គូស្វាមីភរិយានេះ យ៉ាងមហោឡារិក ។

គួរពប់ថា ជាភ័ព្វសំណាងរបស់នាងអម្ពរខ្ពស់ណាស់ កាលនាងនៅក្រមុំមិនបានការខុនកាយ ត្រឡប់ជាមេម៉ាយបានរៀបការមានកិត្តិយសឈ្មោះសម្លេង លើសនារីក្រមុំ

ខ្វះផង ។

លោកពន្យ-សំគឿនស្រឡាញ់ភរិយាណាស់ តាំងពីការរៀប លោកក៏ឈប់ឲ្យអម្ពុទៅធ្វើការឯហាងទៀត ។ លោកឲ្យនាងទៅនៅផ្ទះឬវិទ្យា ឯទួលគោក ដែលលោកប្រុសលោកស្រី ឪពុកម្ដាយលោកបង់ដៃឲ្យនៅពេលរៀបការ ។

ជីវិតអម្ពុនៅរីកសត់ ដែលយើងគិតស្មានថានឹងសាបសូន្យទៅហើយ ក៏ត្រឡប់ជាមានរស្មីរុងរោចន៍ឡើងវិញ គួរឲ្យកោត ។

សព្វថ្ងៃអម្ពុនាងគ្មានគិតភ័យព្រួយ បារម្ភពីរឿងក្រីក្រ អត់ឃ្លានមានស៊ី ដូចជាពេលមុនទៀតហើយ នាងជាកុលាបសួគ៌ពិតប្រាកដ អ្នកបំរើប្រុសស្រីចាំស្ដាប់បញ្ជានាងប្រើគ្រប់ពេលវេលា ។ តែទោះជាបានយ៉ាងនេះហើយក្ដី យូរៗ នាងតែងគិតទៅដល់រឿងដើម ដែលកន្លង

ទៅយ៉ាំងជូរចត់ ជួនកាលវិប្បដិសារីទាំងនោះ វាធ្វើឲ្យនាងព្រួយចិត្តរហូតស្រក់ទឹកភ្នែកព្រូតដោយពុំដឹងខ្លួន ។

ថ្ងៃនេះ ខណៈដែលនាងកំពុងអង្គុយយោលទោងលេងក្នុងសួនច្បារមុខផ្ទះ ប្រកបដោយទឹកមុខញញឹមរីករាយក្នុងចិត្តក៏ស្រាប់តែមានបុរសម្នាក់ ស្លៀកពាក់ខោអាវដាច់ដាច សក់វែងហើយបះប្រូងប្រាងគ្មានរបៀប ពុកមាត់ពុកចង្ការដុះជុំជិតមុខបញ្ជាក់ឲ្យដឹងថាជនទុព្វលភាពនេះ ខានបានកាត់សក់សំអាតកាយមកជាយូរខែហើយ ។

អម្ពរ មិនបានជាយកចិត្តទុកដាក់នឹងមនុស្សនេះប៉ុន្មានទេ នាងនឹកថាជាស្មូមយាចកដែលតែងតែចូលមកសុំទានរឿយៗ ដូចដែលធ្លាប់មានមក ។

តែអនិច្ចា ! កាលបើមនុស្សនេះចូលមកជិតទើបនាងស្គាល់ច្បាស់ថាទិរ៉ាប្ដីមុនរបស់នាងនោះឯង ។ កំហឹងចង់គំនុំទុកកាលពីប៉ុន្មានឆ្នាំមុនរលាយអស់កាលឃើញទិរ៉ាស្ថិតនៅ

ក្នុងសភាពជាស្មូមយាចក ... នៅសល់តែសេចក្ដីអាណិតអាសូរនិងវេទនាភ្នែកជាប់ដក់ក្នុងដួងចិត្ត ។

- បងទិរ៉ា !...

អម្ពរ ហៅឈ្មោះអតីតប្ដីខ្សឹបតិចៗ ក្រោយពីអង្គុយភាំងអស់មួយសន្ទុះ ។

ទិរ៉ាស្រក់ទឹកភ្នែក ខ្សឹកខ្សួល អណ្ដើតអណ្ដក់ ទំរាំហារមាត់ស្ដីរួចថា ៖

អូនអម្ពរ ! អូននៅចាំបងបានដែរឬ ? បងខុសអស់ហើយក្នុងជាតិនេះបងមកសុំអភ័យទោសពីអូន ... សូមអូនលើកលែងទោសឲ្យបងផង ...!

- ខ្ញុំឥតខឹងបងទេ ...! ខ្ញុំព្រមលើកលែងទោសឲ្យទាំងអស់ តើម្ដេចបានជាបងមករកខ្ញុំហើយ ...!

ទិរ៉ាលើកខ្នងដៃជូតទឹកភ្នែក ទើបឆ្លើយនិងសំនួរអតីតភរិយាកំសត់ថា ៖

– បងអត់ដឹងអូនទោកខ្វែងនេះទេ ...! បងកូលមក ប្រាថ្នាសុំតែនតែម៉្យាងប៉ុណ្ណោះ តែ ... ជាបែជន្យ ... បណ្ដាលឲ្យបងបានជួបអូនម្ដងទៀត ... នៅពេលជិតផុត ចប់នៃឆាកជីវិត ... អូនអម្ពរ! តើអូនដឹងទេ ... នៅពេល ដែលបងធ្លាក់ខ្លួន បងនឹកដល់អូន បងប៉ងកសាងខ្លួនបងម្ដង ទៀត ... តែកម្មការលោកីយ៍មិនប្រណីបងសោះ! បង ត្រូវគេដេញចេញពីរោងពុម្ពឈប់ឲ្យធ្វើការ . . . សោកា ប្រពន្ធបងក្រោយមានសហាយ ... បងត្រូវតុលាការកាត់ ទោសឲ្យជាប់គុកអស់មួយឆ្នាំ ក្នុងបទល្បួចកាន់គេ នៅពេល បងចេញពីគុកមកវិញ បងក៏ខូចចិត្ត ... រកប្រកបការងារអ្វី លែងកើត ... បងបណ្ដោយខ្លួនឲ្យរស់នៅរបៀបស្មូមយាចក សោកអណ្ដែតតាមយថាកម្ម ។

និយាយបានត្រឹមណោះ ទិពក៏ណែនដើមករកបារមាត់ បន្តប្រយោគទៅទៀតលែងរួច ។ ទឹកភ្នែកអក៏ព្យូហូរប្រដេញ

ចេញពីរន្ធចក្ខុដូចទឹកធ្លាយទំនប់ ។ គេយំហើយយំទៀត យំមិនព្រមឈប់ ហាក់ដូចជាចង់លាតត្រដាងសេចក្ដីខ្លោចផ្សាក្នុងជីវិតរបស់គេ ដែលនិយាយមិនរួច ឲ្យហូរមកតាមប្រឡាយទឹកភ្នែក ។

អម្ពរ នាងអត់ទ្រាំទប់ចិត្តពុំបាន ក៏ហៀរហូរផលនេត្រតាមទិរ៉ាដែរ ។

ឈប់ស្ងាត់ស្ងៀមអស់ពេលមួយសន្ទុះធំ ទំរាំនាងបាត់អណ្ដឹតអណ្ដក់ ទើបសួរសារជាថ្មីទៅទិរ៉ាថា ៖

- បងទិរ៉ា ! បងជួបខ្ញុំដូច្នេះហើយ បងប្រាថ្នាអ្វីដែរ? បងប្រាប់មកខ្ញុំជូនបងបានទាំងអស់ ..!

ស្ងួមយាបកខំប្រឹងញញឹមទាំងទឹកភ្នែក ។ វាចាស្អកៗទៅកាន់អម្ពរថា ៖

- បងគ្មានត្រូវការចង់បានអ្វី ក្រៅពីនៅបំរើសងបំណុលគុណអូនទំរាំថ្ងៃអស់ជីវិតទេ ...!

- បងចង់នៅជាមួយខ្ញុំ ?

អម្ពរឧទានដោយកិតភ័យ ។

- ត្រូវហើយបងចង់នៅជាមួយអូនអម្ពរ ... នៅគន់ភាពជាប្ដីបំរើអូន ... បងគ្មានត្រូវការអ្វីឲ្យលើសពីនេះទៅទៀតទេ ...!

- បងទិភ ! (អម្ពរនិយាយបញ្ចេញសម្លេងញាំខុសប្រក្រតី) ខ្ញុំសព្វថ្ងៃមិនមែននៅខ្លួនទំនេរទេ ... ខ្ញុំមានប្ដីរួចទៅហើយបង !

- អូស ! អូនមានប្ដី ! អូនមានប្ដី ! បង ... បង... បងលាសិនហើយអូន ! ..

ជនស្លាបយាបត ស្ទុះក្រោកតែទៅក្រៅបងផ្ទះយ៉ាងរហ័ស ។

- ឈប់បងទិភ ! ឈប់សិនបងទិភ !

អម្ពរ ខំប្រឹងស្រែកហៅឈ្មោះស្លាបយាបតឲ្យគេឈប់

មកវិញ   តែអត់ប្រយោជន៍ជនទុព្វលភាពបានរត់ទៅឆ្ងាយហើយ ៗ

ពេលនេះ   បើសិនជាមានអ្នកណារត់តាមទាំងឲ្យទាន់ គេមិនឮមាត់នាយនិយាយ   ទាំងហូរទឹកភ្នែកស្រស្រាំថា៖

- ទេ ! ទេ ! ទេ ! កុំឃាត់បងអូនអម្ពរបណ្ដោយឲ្យបងទៅស្លាប់ចុះ !... អូនមានប្ដីហើយ ... បងមិននៅជិតអូនទៀតទេ ... កុំឲ្យប្ដីអូនគេស្អប់ខ្ពើមបង ... ឯណា-មច្ចុរាជហា ! ហា ! ហា ! ឯណាទៅស្ដេចនៃសេចក្ដីស្លាប់មកឆាបឆក់យកជីវិតខ្វះន័យ របស់ខ្ញុំឲ្យហើយទៅ ... ឲ្យខ្ញុំរស់ធ្វើអ្វីទៀត ... ខ្ញុំមិនចង់រស់ទេ ...!

ទិវា   បោះតែរត់ទៅមុខ   រត់ទៅជួបមនុស្សឥតវិញ្ញាណ ឡានស៊ីក្លូ និងយានគ្រប់ប្រភេទ   នាំគ្នាឈប់ត្រៀមត្រាបណ្ដោយឲ្យមនុស្សឃ្លានស្លាប់នេះ រត់ផុតពីមុខយានរបស់ខ្លួនដោយគេយល់ថាជាមនុស្សវិកលចរិត ៗ

គម្ពរ នាងស្រែកទ្រហោយំទឹកអាណិតអតីតស្វាមី គ្រប់ពេលដែលនាងឃើញស្ទួមយាចកចូលមកសុំទាន ៗ លោកពង្ស-សំអឿនបាននិយាយប្រលោមលួងលោមភរិយា កុំឱ្យសោយសោក តែមិនសូវបានលទ្ធផលប៉ុន្មានទេ ពោះជានៅទីណាកន្លែងណាក៏ដោយ ឲ្យតែនាងក្រឡេកឃើញស្ទួមយាចក នាងក៏យំទឹកឃើញទៅដល់ទិវាមួយរំពេច ៗ

សព្វថ្ងៃទិវាមិនទាន់ស្លាប់នៅឡើយទេ ៗ ដោយអំណាចខ្ទបចិត្តគេក៏ក្លាយទៅជាមនុស្សវិកលចរិត ដើរច្រៀង ដើររាំផ្ទួនយំ ផ្ទួនសើច ៗ ហើយក្រោយមកទៀតក៏បានដំណឹងថា ជនវិកលចរិតនេះត្រូវគេនាំខ្លួនយកទៅព្យាបាលឯមន្ទីរពេទ្យវិកលចរិតឯតាខ្មៅ ( ព្រែកក្នាត ) ក្នុងទីរួមខេត្តកណ្ដាលទៅហើយ ៗ

លោកពង្ស-សំអឿននិងគម្ពរ បាននាំគ្នាទៅឯមន្ទីរពេទ្យ

ម៉ៅ-គុសុមោ
Kusumo MAO



មើលទិភផែរ តែទិវាក្រឡុកខ្លួរ មើលអម្ពរលែងស្គាល់ទៅ

ហើយ ៗ គេគ្មានចាំអ្វីបានក្រៅពីយំនិងសើច ម៉្លៃៗ

ទាល់តែល្ងាចប៉ុណ្ណោះ ៗ

— ចប់បរិបូណ៌ —

អ្នកនិពន្ធ

ហាក់ - ឆៃហុក



រោងពុម្ព ចំរើនរដ្ឋ

តម្លៃ១៥០ ៖ ០០

តម្កល់ទុកតាមលេខ ៧៤៤
ចុះ ថ្ងៃ ទី ៥ ខែ ៥ ឆ្នាំ ១៩៧២
បោះពុម្ពលើកទី១ ចំនួន ២០០០ក្បាល




CLPP